ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣៖៣

មន្ទីរអប់រំយុវជននិងកីឡារាជធានីភ្នំពេញ

*សាលាជំនាន់ថ្មីវិទ្យាល័យព្រែកលៀប*

# ស្នាដៃចូលរួមអបអរសាទរ ទិវាជាតិអំណានលើកទី៦

# លើប្រធានបទ

# "កម្លៃអក្សរសិល្ប៍នៃរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ"

*បេក្ខជន* **ជក់ សុភា** *ភេទប្រុស កើតនៅថ្ងៃ៣ ខែមិថុនា ឆ្នាំ១៩៩៦*

*ជាបង្រៀននៅ សាលាជំនាន់ថ្មីវិទ្យាល័យព្រែកលៀប រាជធានីភ្នំពេញ*

*ទូរសព្ទ៖* 086 204 699

ព.ស. ២៥៦៤ គ.ស. ២០២១

# តម្លៃអក្សរសិល្ប៍នៃរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ

## សេចក្តីផ្តើម

អក្សរសិល្ប៍ ប្រៀបបានជាផ្ទាំងទស្សនីយភាពដ៏ប្រណិតដែលបានលាតត្រដាងនូវតថភាពសង្គមតាមរយៈសម័យកាលនីមួយៗ។ ក្នុងនោះរឿងរាមកេរ្តិ៍ ជាស្នាដៃដ៏ពិសិដ្ឋមួយដែលបានដក់ជាប់ក្នុងសតិអារម្មណ៍របស់ប្រជាជាតិខ្មែរ រាប់ចាប់តាំងពីព្រះមហាក្សត្ររហូតដល់ប្រជានុរាស្ត្រហើយតាំងពីបុរាណកាលមកដល់បច្ចុប្បន្ន។ វណ្ណកម្មរឿងរាមកេរ្តិ៍ស្ថិតក្នុងចលនាព្រាហ្មណ៍និយមព្រមទាំងត្រូវបានក្រសួងអប់រំជាតិដាក់បញ្ចូលក្នុងកម្មវិធីសិក្សាកម្រិតមធ្យមសិក្សានិងឧត្តមសិក្សានាឆ្នាំ១៩៥៨-១៩៧៥។[1] ពិពិធភាពនៃរឿងរាមកេរ្តិ៍ ត្រូវបានគេយកទៅប្រើចម្រុះពណ៌ក្នុងវិស័យសិល្បៈខ្មែរ ដូចជា ចម្លាក់ គំនូរ របាំ ល្ខោន ភាពយន្ត... ហើយជាពិសេសនោះគឺស្នាដៃអក្សរសិល្ប៍នេះតែម្តង។ វាជានិម្មិតកម្មអក្សរសិល្ប៍ខ្មែរមួយ ដែលបានបង្កប់និងបង្ហាញនូវ គំនិត ទស្សនវិជ្ជាក្នុងការគិត វិភាគ ពិចារណា សម្រាប់ការបង្កើតគ្រួសារ គូទំនាស់បងប្អូន និងការធ្វើសឹកសង្គ្រាមទៀតផង។ មិនត្រឹមតែប៉ុណ្ណោះរឿងនេះក៏បង្ហាញពីភាពឈ្លាសវៃរបស់អ្នកកវីនិពន្ធខ្មែរ ក៏ទោះបីជារឿងរាមកេរ្តិ៍ជាកូនបង្កើតរបស់រឿងរាមាយណៈក៏ដោយ ក៏លោកកវីខ្មែរបានកែប្រែសាច់រឿងមួយចំនួនបញ្ចូលនូវលក្ខណៈ រសជាតិបែបខ្មែរទៅវិញ។

ជាការពិតណាស់រឿងរាមកេរ្តិ៍ត្រូវបានបន្តអត្ថិភាពមកដល់បច្ចុប្បន្ន ទាំងក្នុងកម្មវិធីសិក្សាថ្នាក់មធ្យមសិក្សា និងថ្នាក់ឧត្តមសិក្សា។ លើសពីនេះរឿងរាមកេរ្តិ៍បាន ផ្សារភ្ជាប់ខ្លួនទៅនឹង ជីវភាព ជំនឿ ប្រពៃណី ទំនៀមទម្លាប់ និងសិល្បៈក្នុងសង្គមខ្មែរទៀតផង។ មកដល់នឹងបច្ចុប្បន្នយើងបានរកឃើញនូវឯកសាររឿងរាមកេរ្តិ៍មួយចំនួនដែលសេសសល់ក្រោយសង្គ្រាមដ៏រ៉ាំរ៉ៃ។ ទាំងនេះជាសមុច្ច័យមួយដ៏សំខាន់ក្នុងការសិក្សាឈ្វេងយល់ពីឥទ្ធិពលនៃរឿងរាមកេរ្តិ៍មកលើសង្គមខ្មែរ។

## ១. ទិដ្ឋភាពទូទៅនៃរឿងរាមកេរ្តិ៍

### ១.១. ទិដ្ឋភាពប្រវត្តិ

រឿងរាមកេរ្តិ៍ត្រូវបានចម្លងចេញពីរឿងរាមាយណៈដែលជាប្រភេទវីរកថាមួយរបស់ឥណ្ឌា។ រឿងរាមាណៈត្រូវបានអ្នកស្រាវជ្រាវសាន់កាទីយ៉ា អ្នកស្រាវជ្រាវវត្ថុបុរាណនាឆ្នាំ១៩៦៧ បានប្រើកាំស្មីក្នុងការកំណត់ការចាប់កំណើតរបស់រឿងរាមាយណៈនៅស.វ.ទី៣មុនគ.ស. និងសម្រេចសព្វគ្រប់នៅស.វ.ទី៤ក្រោយគ.ស.។ ជាការពិតស្នាដៃនេះចាប់កំណើតពីក្នុងមជ្ឈដ្ឋានប្រជាជនដែលបាននិយាយផ្សព្វផ្សាយពីសម័យកាលមួយទៅសម័យកាលមួយអស់រយៈកាលរាប់ពាន់ឆ្នាំ ហើយត្រូវបានគេចម្លងចារផ្សេងៗគ្នាធ្វើឱ្យកាន់តែរស់រវើក។ តាមការតំណាលក្នុងព្រេងកថាអ្នកដែលបានចងក្រងស្នាដៃរាមាយណៈជាឃ្លាកាព្យដំបូងគេបំផុតគឺ វាល្មិកិ។[2]

ដូចដែលយើងបានដឹងហើយថា រឿងរាមាយណៈត្រូវបានពេញនិយមក្នុងបណ្តាលប្រទេសអាស៊ីអាគ្នេយ៍ ហើយវាក៏បានហូរចូលមកកម្ពុជាក្រោមរូបភាពជារឿងរាមកេរ្តិ៍។ រឿងរាមកេរ្តិ៍ត្រូវបានស្តែងឱ្យឃើញយ៉ាងប្រត្យក្សនាសម័យអង្គរ ដូចជាប្រាសាទកោះកេរ្តិ៍(ដើមស.វ.ទី១០) ប្រាសាទបន្ទាយស្រី(ស.វ.ទី១០) ប្រាសាទបាពួន(ដើមស.វ.ទី១១) ប្រាសាទអង្គរវត្ត(ក្នុងស.វ.ទី១២នៃរាជ្យរបស់ព្រះបាទសូរ្យវរ្ម័នទី២) និងប្រាសាទបន្ទាយសំរ៉ែ(ស.វ.ទី១២)[3]។ ម្យ៉ាងតាមការស្រាវជ្រាវរបស់អ្នកប្រាជ្ញនៅស្រុកឥណ្ឌានិងអឺរ៉ុបបានឱ្យដឹងថា "រឿងរាមាយណៈនេះត្រូវបានផ្សាយដោយសេចក្តីប្រែរបស់អ្នកស្រុកម៉ងគ័លនៃប្រទេសឥណ្ឌាប៉ែកខាងត្បូង ចូលមកតាមប្រទេសជ្វានិងម៉ាឡេស៊ី ទើបចូលមកដល់ប្រទេសខ្មែរក្នុងសម័យអង្គរ ហើយផ្សាយចេញពីប្រទេសខ្មែរទៅ

[1] *ឃឹង ហុកឌី, ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ, បណ្ណាគារអង្គរ, ២០០៣, ទំ. ៩៩*

[2] *ស៊ុំ ឈុំប៊ុន, អក្សរសិល្ប៍ឥណ្ឌា, ភូមិន្ទភ្នំពេញ, ១៩៩៩, ទំ.៦៨*

[3] *សរ សារុន, រាមកេរ្តិ៍, ១៩៧៥, ទំ.២*

ប្រទេសថៃនិងប្រទេសលាវបន្តទៀត។ សព្វថ្ងៃនេះប្រទេសខ្មែរ ថៃ លាវ ជនជាតិទាំងនេះនៅនិយមរឿងរាមកេរ្តិ៍នៅឡើយ[4]។ នេះសបញ្ជាក់ឱ្យឃើញថា រឿងរាមកេរ្តិ៍អាចនឹងចាប់ផ្តើមប្រតិស្ឋឡើងក្នុងសង្គមខ្មែរតាំងពីសម័យមហានគរមកម្ល៉េះ ហើយរឿងរាមកេរ្តិ៍ត្រូវបានវិវត្តខ្លួនសន្សឹមៗចូលទៅសង្គមខ្មែរហើយត្រូវបានប្រជាជនគាំទ្រ។ ក៏ទោះបីជាក្រោយការធ្លាក់ចុះនៃចក្រភពអង្គរ សាសនាព្រាហ្មណ៍ត្រូវបន្ថយឥទ្ធិពលយ៉ាងណាក៏ដោយ ក៏កវីនិពន្ធខ្មែរបានខិតខំកែខៃអត្ថន័យរឿងនេះឱ្យមានភាពលាយឡំគ្នាជាមួយពុទ្ធសាសនា ត្បិតនាសម័យកណ្តាលប្រជាជនខ្មែរបានងាកមកគោរពពុទ្ធសាសនាហិនយាន និងងាកចាប់អារម្មណ៍លើរឿងជាតកទៅវិញ។

### ១.២. ទស្សនាទានស្តីពីការកំណត់តែខនិពន្ធ

រឿងរាមកេរ្តិ៍ដែលយើងសិក្សាសព្វថ្ងៃនេះ យោងតាមការស្រាវជ្រាវរបស់លោក លាង ហាប់អាន លោក សរ សារុន លោក ឱម ណាត្រី ថាជាឯកសាររបស់អ្នកអង្គម្ចាស់វឌ្ឍឆាយាវង្ស តាមឯកសារនេះពុំបានប្រាប់ឈ្មោះ និងពេលវេលានោះទេ។ ប៉ុន្តែលោកបានបញ្ជាក់ថា រឿងដែលកត់ត្រាជាលាយលក្ខណ៍អក្សរ ហើយដែលត្រឹមត្រូវជាងគេ គឺរឿងដែលបោះពុម្ពចេញពីវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ នៃក្រសួងធម្មការ បោះពុម្ពលើកទី១ក្នុងព.ស. ២៤៨០ គឺជាច្បាប់របស់អ្នកអង្គម្ចាស់វឌ្ឍឆាយាវង្សផង និង ជាច្បាប់របស់សាលាបារាំងចុងបូព៌ាប្រទេសនាក្រុងហាណូយ។[5]

តាមការស្រាវជ្រាវនិងការឱ្យយោបល់របស់លោក ញ៉ុក ថែម អតីតសាស្ត្រាចារ្យនៅមហាវិទ្យាល័យ អក្សរសាស្ត្រនិងមនុស្សសាស្ត្រលោកថា៖

- ខ្សែទី១ ដល់ទី១០ មានកាលបរិច្ឆេទនិងការសរសេរប្រមាណជាក្នុងស.វ.ទី១៧-១៨ នៃគ.ស. គឺពីរជ្ជកាលព្រះករុណាជ័យជេដ្ឋាទី៤ ដល់ព្រះបាទសម្តេចព្រះអង្គអេង។
- ហើយខ្សែទី៧៥ដល់ ៨០ ប្រហែលជាតាក់តែងឡើងក្នុងគ្រឹស្តស.វ.ទី១៨-១៩ រជ្ជកាលព្រះអង្គអេងមកដល់ព្រះបាទអង្គឌួង។[6]

តែបើតាមការសិក្សារបស់លោកស្រី ពៅ សាវរស វិញ លោកស្រីបានសន្និដ្ឋានថា រឿងរាមកេរ្តិ៍ត្រូវបាននិពន្ធឡើងនៅស.វ.ទី១៦-១៧។[7]

ដូច្នេះយើងសន្និដ្ឋានបានថា រឿងរាមកេរ្តិ៍ខ្មែរ គឺជារឿងដែលទទួលឥទ្ធិពលពីរឿងរាមាយណៈឥណ្ឌានិងបាននាំចូលមកក្នុងប្រទេសកម្ពុជាយើងតាំងពីយូរលង់ណាស់មកហើយគឺតាំងពីស.វ.ទី៥-៦ មកម្ល៉េះដោយសម្អាងទៅលើសន្លឹកមាសមួយសន្លឹក(រូបហនុមានច្បាំង)របស់អ្នកអង្គបុរី[8] និងតាំងពីស.វ.ទី១០ បើយោងទៅតាមចម្លាក់រឿងរាមកេរ្តិ៍ដែលមាននៅតាមប្រាសាទបុរាណខ្មែរ ប៉ុន្តែរឿងនេះទើបតែត្រូវបានចងក្រងឡើងនៅនាស.វ.ទី១៧-១៨តែប៉ុណ្ណោះ។[9]

ពាក់ព័ន្ធនឹងរឿងរាមកេរ្តិ៍នេះដែរ នៅក្នុងសម័យកណ្តាលត្រូវបានគេហាមឃាត់មិនឱ្យផ្សាយក្នុងសង្គមខ្មែរ។ យោងតាមលោក សរ សារុន បានបញ្ជាក់នៅក្នុងសៀវភៅសង្ខេបរឿងរាមកេរ្តិ៍ បានបង្ហាញថាមុនសម័យឯករាជ្យ រឿងរាមកេរ្តិ៍នេះត្រូវបានគេហាមឃាត់មិនឱ្យផ្សាយចេញនៅស្រុកខ្មែរព្រោះវាជារឿងមានទម្រង់និងគោលគំនិតប្រឆាំងនឹងសាសនាព្រះពុទ្ធ។ ដូច្នេះគ្រប់ទម្រង់សិល្បៈ វប្បធម៌ផ្សាយពីរឿងរាមកេរ្តិ៍ក៏ត្រូវហាមឃាត់ដែរ។ ព្រះរាមជាតួអង្គសំខាន់ក្នុងរឿង និងតំណាងសាសនាព្រះនារាយណ៍

---

[4] *ឱម ណាត្រី, សិក្សាអក្សរសាស្ត្រ រឿងរាមកេរ្តិ៍(ពីភាគ១ដល់ភាគ១០), ១៩៦០,ទំ. ៣*

[5] *កក់ ច័ន្ទថាត, គំនូរបុរាណរឿងរាមកេរ្តិ៍, ភ្នំពេញ, ១៩៩៦, ទំ.២៥*

[6] *-ដ-, ទំ. ២៥*

[7] Saveros Pou, Ramketi(XVI-XVII) *រាមកេតិ* Paris(6),1997

[8] *ទីតូ, ការបញ្ជាក់ពីប្រភពរឿងរាមកេរ្តិ៍ នៅក្នុងកាសែតរស្មីកម្ពុជា ឆ្នាំទី៨ លេខ២២២៥ ថ្ងៃព្រហស្បតិ៍ទី១៧ ខែសីហា ឆ្នាំ២០០០*

[9] *ជា វណ្ណី, រាមកេរ្តិ៍ក្នុងសង្គមខ្មែរ, និក្ខេបបទ,រាជបណ្ឌិត្យសភា, ២០១៣, ទំ.១០*

ហើយសាសនានេះមានឥទ្ធិពលខ្លាំងណាស់នៅប្រទេសខ្មែរ នៅស.វ.ទី១១។ ការហាមឃាត់មិនឱ្យចេញផ្សាយរឿងរាមកេរ្តិ៍នេះមានច្រើនបែបៈ

- មិនឱ្យមានសាស្ត្រានិងឯកសារផ្សេងៗដែលទាក់ទងនឹងរឿងរាមកេរ្តិ៍នៅក្នុងលំនៅដ្ឋាន។
- មិនឱ្យជជែកគ្នាលេងរឿងរាមកេរ្តិ៍។
- មិនឱ្យយករឿងរាមកេរ្តិ៍ ធ្វើជាកម្មវត្ថុសិក្សា ត្រូវជំនួសដោយសាស្ត្រាជាតកវិញ។
- មិនឱ្យចំលងសាស្ត្រារឿងរាមកេរ្តិ៍ឡើងវិញ។
- ត្រូវបំផ្លាញចោល ដើម្បីឱ្យបាត់ស្រមោលតែម្តង ទើបក្នុងការបោះពុម្ពផ្សាយ ក្រោយមកបាត់បង់ភាគច្រើននៃរឿងរាមកេរ្តិ៍ គឺបាត់បង់ពីខ្សែ១១ ដល់ ខ្សែ៧៥ "៦៤ខ្សែ" (ការដែលបាត់ពីខ្សែ១១ ដល់ខ្សែ៧៤ នេះគ្មាននរណាម្នាក់ដឹងបានឡើយថា ខ្សែនេះគេមិនទាន់បានសរសេរឬក៏បាត់មែន) ឯខ្សែដែលសេសសល់គឺការលាក់ទុកដោយស្ងាត់កំបាំងរហូតដល់នាង កញ្ញាម្នាក់ ជនជាតិបារាំងឈ្មោះ (Karpelés)មករៀបចំ ឯកសារឡើងវិញ នៅវិជ្ជាស្ថានទើបមានការបោះពុម្ពរឿងរាមកេរ្តិ៍ រហូតដល់សព្វថ្ងៃនេះ។ [10]

### ១.៣. អ្នកអង្គម្ចាស់វឌ្ឍឆាយាវង្សនិងរឿងរាមកេរ្តិ៍

រឿងរាមកេរ្តិ៍របស់អ្នកអង្គម្ចាស់វឌ្ឍឆាយាវង្សត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សាអក្សរសាស្ត្រនៅមធ្យមសិក្សានិងឧត្តមសិក្សានៅឆ្នាំ១៩៥៨-១៩៧៥។

ជាការពិតណាស់ ទាក់ទងនឹងឯកសារប្រវត្តិនៃព្រះអង្គម្ចាស់ស៊ីសុវត្ថិវឌ្ឍឆាយាវង្សយើងក៏មិនសូវមានពេបប្រទះនោះឡើយ។ យ៉ាងណាមិញយើងងាកក្រឡេកទៅមើលសៀវភៅ ប្រវត្តិសាស្ត្រកម្ពុជា និងវរជនខ្មែរ របស់លោក សាគូ សាម៉ុត វិញ លោកក៏បានឡើងចំណុចសំខាន់មួយអំពីរឿងរាមកេរ្តិ៍ លោកបានបរិយាយថា "ទ្រង់ (ព្រះអង្គម្ចាស់ស៊ីសុវត្ថិវឌ្ឍឆាយាវង្ស) មានបណ្ណាល័យឯកជន មានរក្សាទុកសាស្ត្រារឿងរាមកេរ្តិ៍ ដែលពេលក្រោយមកនៅឆ្នាំ១៩៣៧ អ្នកស្រី ស៊ុនសាន កាប៉ុយឡេ SUZANNE KAPARLES នាយិកាវិជ្ជាស្ថានពុទ្ធសាសនាជាមួយសាលាបារាំងចុងបូព៌ា បានបោះពុម្ពផ្សាយយ៉ាងទូលាយ" ត្រង់នេះដូចដែលយើងបានពិនិត្យមើលខាងលើ អាចសបញ្ជាក់ឱ្យឃើញថា ព្រះអង្គម្ចាស់ស៊ីសុវត្ថិ វឌ្ឍឆាយាវង្ស ជាអ្នករក្សានូវសាស្ត្រារាមកេរ្តិ៍ទាំងនេះ ហើយបានវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ សុំការអនុញ្ញាតយកទៅបោះពុម្ពផ្សាយ។

ព្រះអង្គម្ចាស់ស៊ីសុវត្ថិវឌ្ឍឆាយាវង្ស ទ្រង់ប្រសូត ថ្ងៃទី ១៣ ខែ កញ្ញា គ.ស. ១៨៩១ នៅក្រុងភ្នំពេញ។ ទ្រង់មានបិតានាមព្រះអង្គម្ចាស់ ស៊ីសុវត្ថិវឌ្ឍនាវង្ស ដែលជា បុត្រាហ្លួង សីវិសុវត្ថិ និងអ្នកម្នាង ពុយ និងមាតានាម អ្នកម្នាង ស្បៀរឿង ។

បន្ទាប់ពីបញ្ចប់សញ្ញាបត្រមធ្យមសិក្សា ទ្រង់បានយាងទៅសិក្សា នៅសាលាវិទ្យាសាស្ត្រនយោបាយ នៅ ប៉ារីស ប្រទេសបារាំង។ ក្រោយពីបញ្ចប់ការសិក្សានៅប្រទេសបារាំងទ្រង់ក៏បានយាងមកមាតុភូមិវិញ ហើយបានចូលបម្រើការផ្នែកតុលាការ។ ព្រះអង្គក៏បានទទួលដំណែងជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្រោយពេលព្រះអង្គស៊ីសុវត្ថិ យុត្តិវង្ស ចូលទិវង្គតភ្លាម។ ព្រះអង្គក៏ធ្លាប់ជានាយករដ្ឋមន្ត្រីទី ៥ នៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ ដែលកាលនោះតំណាងឱ្យ គណបក្សប្រជាធិបតេយ្យ ឡើងកាន់អំណាចពីថ្ងៃទី ២៥ កក្កដា គ.ស. ១៩៤៧ ដល់ ថ្ងៃទី ២០ កុម្ភៈ គ.ស. ១៩៤៨ ។

ព្រះអង្គម្ចាស់ស៊ីសុវត្ថិវឌ្ឍឆាយាវង្ស មានមហេសី ៣អង្គ ព្រះអង្គម្ចាស់ក្សត្រីយ៍ ស៊ីសុវត្ថិ សុជាវង្សី ( ឬហៅ សម្តេចចៅហ្វាវង្សី ជាបុត្រីហ្លួង ស៊ីសុវត្ថិ មុនីវង្ស និងព្រះអង្គម្ចាស់ក្សត្រីយ៍ ស៊ីសុវត្ថិ ស៊ីសុជា ) មានបុត្រ ៦អង្គ។ អ្នកម្នាង អាលី មេណុដ មានបុត្រ១អង្គ។ អ្នកអង្គម្ចាស់ក្សត្រីយ៍ នរោត្តម សុជាវង្សី ( បុត្រីព្រះអង្គម្ចាស់ នរោត្តម ច័ន្ទលេខា )មានបុត្រ១៧អង្គ។

---

[10] *កក់ ច័ន្ទថាត, គំនូរបុរាណរឿងរាមកេរ្តិ៍, ដ-ឯ-ម., ទំ.២៤*

គួរបញ្ជាក់ផងដែរយើងឃើញថា នៅសៀវភៅ ប្រវត្តិសាស្ត្រកម្ពុជា និងវរជនខ្មែរ បានបញ្ជាក់ពីបុត្រាបុត្រីរបស់ទ្រង់ស៊ីសុវត្ថិខ្សែឆាយាវង្សមាន ២៥អង្គ។ តែយោងតាមការរៀបរាប់របស់គេហទំព័រ Colorise & Old photos of Cambodia ឃើញមានតែត្រឹមតែ២៤អង្គប៉ុណ្ណោះ។ ព្រះអង្គម្ចាស់ស៊ីសុវត្ថិខ្សែឆាយាវង្សសុគតនៅថ្ងៃទី៣០ ខែមករា គ.ស.១៩៧២ នៅក្រុងភ្នំពេញ(ព្រះជន្មាយុ៨១ ព្រះវស្សា)។

## ២. តម្លៃអក្សរសិល្ប៍នៃរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ

ជាការពិតណាស់ រឿងរាមាយណៈក្លាយជាទីពេញនិយមនិងគាំទ្រពីសំណាក់ជនជាតិនៅបណ្ដាប្រទេសអាស៊ីអាគ្នេយ៍។ រឿងរាមាយណៈត្រូវបានប្រែប្រួលលក្ខណៈ ពណ៌សម្បុរទៅតាមទីតាំងភូមិសាស្ត្ររបស់ប្រទេសនីមួយៗ។ តួយ៉ាងរឿងរាមាយណៈត្រូវបានក្លាយជារឿងរាមគៀនរបស់ថៃ រឿងកាកាវីន រាមាយណៈ(Kakawin Ramayana)របស់ឥណ្ឌូណេស៊ី រឿងព្រះលក្សណ៍ព្រះរាម (Phra Lak Phra Lam)របស់ឡាវ រឿងហិកាយ៉ាត់ ស្រីរាមា (Hikayat Seri Rama)របស់ម៉ាឡេស៊ី រឿងយ៉ាម៉ាហ្សាដាវ (Yama Zatdaw)របស់ភូមា រឿងមហារាឌី ឡាវ៉ាណា (Maharadia Lawana)របស់ ហ្វីលីពីន និងរឿងរាមកេរ្តិ៍ របស់កម្ពុជា។ មិនខុសពីប្រទេសដទៃ រឿងរាមាយណៈត្រូវបានចូលមកកម្ពុជា ហើយត្រូវបានកវីខ្មែរ ស្លកែខៃច្នៃប្រឌិតថែមថយផ្សេផ្សំឱ្យមានលក្ខណៈរសជាតិលាយឡំជារបស់ខ្មែរ។ ត្រង់នេះហើយដែលនាំឱ្យការគ្រាំទ្រទៅលើរឿងរាមកេរ្តិ៍បានដក់ជាប់ក្នុងគំនិតខ្មែរ រហូតក្លាយជាជំនឿនិងទំនៀមទម្លាប់ទៀតផង។ ក្នុងនោះរឿងរាមកេរ្តិ៍បានចាក់ឫសចូលទៅក្នុងផ្នត់គំនិត អរិយធម៌ខ្មែរដែលមានទាំងផ្នែកសង្គមធម៌ និងវប្បធម៌យ៉ាងជ្រៅទៀតផង។

### ២.១. តម្លៃអក្សរសិល្ប៍នៃរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរឆ្លុះបញ្ចាំងតាមរយៈសង្គមធម៌

នៅក្នុងមែកធាងនៃសង្គមធម៌មានច្រើនសម្បូរបែប ហើយគេចែកវាជាបីធំៗគឺគ្រឿងសង្គម របបសង្គម និងទម្រង់សង្គម។ សង្គមធម៌ត្រូវបានស្ថិតជាប់នៅក្នុងប្រជាជននៃសង្គមនីមួយៗ។ពិតណាស់រឿងរាមកេរ្តិ៍នេះក៏បានបញ្ជ្រៀតខ្លួនចូលទៅក្នុងទិដ្ឋភាពនៃសង្គមធម៌ផងដែរ។ការបញ្ជ្រៀតចូលនេះពុំមែនជាការបង្ហាញលេចចេញឬស្ដែងចេញក្រោមទម្រង់ជារូបភាពនោះទេ។ ផ្ទុយទៅវិញវាស្ដែងឱ្យឃើញតាមរយៈផ្នត់គំនិត និងទស្សនៈវិស័យ ចក្ខុវិស័យក្នុងការធ្វើនយោបាយ ឬក្នុងកិច្ចការរដ្ឋជាដើម។

#### ២.១.១. វិស័យនយោបាយ

បើគេនិយាយពីរបៀបធ្វើសឹកសង្គ្រាម ឬគ្រប់គ្រងប្រទេសបែបតថភាពរបស់ប្រទេសចិន គឺគេតែងនឹកទៅដល់រឿងសាមកុក តែបើគេនិយាយពីរបៀបធ្វើសង្គ្រាមបែបរឿងរឿងរីកថា នោះគេរមែងគិតទៅដល់រឿងរាមកេរ្តិ៍នេះឯង។ រឿងរាមកេរ្តិ៍ក៏បានបង្ហាញពីយុទ្ធសាស្ត្រក្នុងការធ្វើនយោបាយក្នុងប្រទេស និងការធ្វើនយោបាយក្រៅប្រទេស តួយ៉ាងដូចជាចំណងការទូតជាដើម។

**ក. នយោបាយក្នុងប្រទេស**

រដ្ឋនីមួយៗគេត្រូវការ ការគ្រប់គ្រងដ៏ហ្មត់ចត់ ដើម្បីធ្វើឱ្យសង្គមមានស្ថេរភាពនិងមានការរីកចម្រើន។ យ៉ាងណាមិញតួនាទីដ៏សំខាន់នោះគឺអ្នកដឹកនាំប្រទេស។ អ្នកដឹកនាំត្រូវគិតគូរទៅលើបញ្ហាផ្សេងៗ ហើយក៏ត្រូវមានទំនួលខុសត្រូវលើការនិយាយស្តីរបស់ខ្លួន។ ដ្បិតទម្ងន់នៃពាក្យពេចន៍របស់មេដឹកនាំ អាចនាំឱ្យសង្គមមានភាពច្របូកច្របល់ ចលាចលឬ រីករវជាដើម។ ក្នុងន័យនេះ អ្នកដឹកនាំត្រូវគោរពលើពាក្យសត្យរបស់ខ្លួន។ តួយ៉ាងនៅក្នុងរឿងរាមកេរ្តិ៍ចំណងបញ្ហាដ៏ធំដែលនាំឱ្យដំណើររឿងមានការវិវត្តទៅមុខ ក៏ដោយការគោរពទៅលើពាក្យសត្យរបស់ព្រះបាទទសរថផងដែរ។ ដោយព្រះអង្គសន្យាជាមួយព្រះនាងកៃកេសីថានឹងប្រគល់រាជសម្បត្តិឱ្យព្រះភិរុត។ តែផ្ទុយទៅវិញ ការសន្យារបស់ទ្រង់បានខុសទៅនឹងប្បវេណីក្សត្រដែលត្រូវបុត្រច្បងជាព្រះរាជានុសិទ្ធិ។ ព្រះអង្គបានឈ្វេងចង់បំបែកនគរដោយកុំឱ្យខុសទៅនឹងប្រពៃណីក្សត្រ។ តែត្រូវបាននាងកៃកេសីជំទាស់ ទើបព្រះអង្គយល់ព្រមឱ្យព្រះភិរុតឡើងសោយរាជ្យ ដោយរក្សានូវពាក្យសត្យរបស់ខ្លួន។ ការគោរពពាក្យសត្យនេះក៏បានចូលរួមពីសំណាក់ព្រះរាមដែលព្រះអង្គព្យាយាមបំពេញព្រះកិត្តិយសឱ្យព្រះបិតាជាព្រះមហាក្សត្រ។ នេះសឱ្យឃើញតម្លៃនៃពាក្យសត្យរបស់អ្នកដឹកនាំ

ពិតជាសំខាន់និងមានតម្លៃ សម្រាប់គ្រប់គ្រងរដ្ឋមួយឱ្យបានល្អ។ ត្រង់នេះវាជាទស្សនាទានមួយដ៏សំខាន់ក្នុងការដឹកនាំរដ្ឋនីមួយៗ ដែលមេដឹកនាំពុំចេះតែនិយាយឱ្យតែរួចហើយពុំធ្វើដែលនាំឱ្យមានការថ្នាំងថ្នាក់ចិត្តពីរាស្ត្រនាំឱ្យមានការប្រឆាំងបះបោរកើតឡើង។

មួយវិញទៀត ក្នុងនាមជាអ្នកដឹកនាំមិនត្រូវគិតតែពីប្រយោជន៍ផ្ទាល់ខ្លួនរហូតដល់បាត់បង់ប្រយោជន៍រួមនោះទេ។ តួយ៉ាងក្រុងលង្កាដែលជាទីស្ញប់ស្ញាត់បានត្រូវឆេះខ្ទេចខ្ទីដោយសារតែក្រុងរាពណ៍ចង់បាននាងសីតាតែមួយគត់។ ទោះបីជាមានហោរាទាយដ៏ពូកែគឺពិភេក ទស្សន៍ទាយថា បើមិនប្រគល់សីតាទៅវិញទេនោះក្រុងលង្កានឹងរលាយ។ មិនត្រឹមតែមិនស្តាប់មតិរបស់នាម៉ឺនមន្ត្រីនោះទេ តែរាពណ៍បានវាយពិភេកមួយស្នែកជើងទៀត។ ជាមួយគ្នានេះដែរយើងងាកក្រឡេកមើលតួអង្គមហិង្សារាជវិញ ដើម្បីរក្សាអំណាចនិងឥទ្ធិពលរបស់ខ្លួនមហិង្សារាជ តែងតែសម្លាប់ក្របីឈ្មោលទាំងអស់នៅក្នុងហ្វូង ក្នុងគោលបំណងមិនឱ្យមានអ្នកណាជ្រៀតជ្រែតខ្លួនបានឡើយ រហូតដល់នាងក្របីញីកើតបានទូភី ដោយយកទៅលួចលាក់ចិញ្ចឹមនោះបានធំពេញរូបរាងក៏បានសម្លាប់ឪពុករបស់ខ្លួនវិញ។មហិច្ឆតារបស់ទូភីក៏មិនខុសពីឪពុកគឺសម្លាប់គ្រប់ក្របីឈ្មោលទាំងអស់។ តែចុងបញ្ចប់ទូភីត្រូវចាញ់ដៃរបស់ពាលីកាត់ក ដោយសារខ្លួនថ្លោះធ្លោយប្រាប់ពីបារមីដែលធ្វើឱ្យទូភីតែងតែឈ្នះនោះគឺមានទេវតាថែរក្សា។ ត្រង់នេះបានជាទស្សនាទានមួយសម្រាប់ការដឹកនាំ ឬគ្រប់គ្រងប្រទេសមួយប្រសិនបើខ្លួនគិតតែពីអំណាច ក្តីសុខ លាភសក្ការៈ ប្រយោជន៍ខ្លួនជាធំនោះ នឹងនាំឱ្យមានក្តីវិនាសជាក់ជាមិនខាន។

ជាក់ស្តែងនាពេលថ្មីៗនេះ នៅថ្ងៃសុក្រ ៩កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២២ ខែមករា ឆ្នាំ ២០២១ ក្នុងឱកាសសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការអគារ ទីស្តីការក្រសួងសាធារណការ និងដឹកជញ្ជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានមានប្រសាសន៍ទាក់ទងទៅនឹងរឿងរាមកេរ្តិ៍ ដែលចែកជាទស្សនាទានដល់មន្ត្រីក្រោមឱវាទ កុំឱ្យយកភរិយាមករញ៉េរញ៉ៃក្នុងការិយាល័យរបស់ខ្លួន។ ដោយសម្តេចបានលើកត្រង់វគ្គចម្បាំងរវាងពាលី និងទូភីថា៖ "អញ្ចឹងប្រពន្ធទៅលើកការសីអត់បានទេ កុំឆ្ងល់ មនុស្សម្នាក់ៗសុទ្ធតែមានមនុស្សការពារខ្លួន មិនអាចចាំយកអ្នកដទៃទៅការពារខ្លួន ព្រោះអញ្ចេះ ប្រយ័ត្នចូលអា ទូភី។ ពាលី(ស្វា) មិនច្បាំងគ្នាជាមួយនឹង ទូភី(ក្របី ក្នុងរឿងរាមកេរ្តិ៍)។ ល្បីអា ទូភី (ប្រយុទ្ធមិនឈ្នះ)។ ពាលី ចេះតែសួរថា អ្ហែងពូកែនឹងអី? ទូភី ឆ្លើយថា ពូកែនឹងទេវតានៅក្នុងស្នែង។ ដល់តែសួរចុះសួរឡើង(ច្រើនដងពេល) ទូភី ឆ្លើយខុសមួយម៉ាត់ទេ គឺអញពូកែនឹងស្នែង ភ្លេចពាក្យទេវតា ពាលី (ក៏)កាត់កអា ទូភី (បាន)បាត់ទៅ។ ហ្នឹងរឿងមួយ តែរឿងមួយទៀតដែលសំខាន់ជាងនេះ គឺវាមិនគប្បីភ្នែករបស់មន្ត្រីធ្វើការជាមួយយើង។ ចាំបាច់អីឱ្យប្រពន្ធមកត្រួតដល់ការិយាល័យ កន្លែងធ្វើការរបស់ប្តីនោះ។[11]" ត្រង់នេះរឹតតែសបញ្ជាក់ឱ្យឃើញពីឥទ្ធិពលនៃរឿងរាមកេរ្តិ៍បានជ្រួតជ្រាបដល់ថ្នាក់ដឹកនាំស្ទើរគ្រប់សម័យកាល ក្នុងកិច្ចការគ្រប់គ្រងប្រទេស គ្រប់គ្រងរដ្ឋបាលឱ្យបានប្រសើរតាមរយៈការដកស្រង់នូវ ទស្សនវិស័យ ទស្សនាទាន ផ្សារភ្ជាប់នឹងកិច្ចការដ្ឋមកបរិយាយ។

**ខ. នយោបាយក្រៅប្រទេស**

ប្រទេសជាតិនីមួយៗមិនអាចរស់នៅតែឯកឯងនោះបាន គេត្រូវការការពឹងពាក់អាស្រ័យគ្នាទៅវិញទៅមកជាចាំបាច់។ ដូច្នេះហើយទើបគេបង្កើតចំណងការទូតជាមួយបណ្តាប្រទេសជាមិត្តទាំងឡាយ។ យ៉ាងណាទោះបីជាមានបញ្ហាណាមួយ ក្នុងគ្រាមានអាសន្នក៏គេអាចជួយគ្នាបាន។ ជាក់ស្តែងកម្ពុជានាពេលបច្ចុប្បន្នមានចំណងការទូត១៧៤ប្រទេសលើពិភពលោក។ តាមរយៈចំណងការទូតនេះ ក្នុងកំឡុងពេលមានវិបត្តិកូវីដ១៩ រាជរដ្ឋាភិបាលកម្ពុជាបាន ជួយជាជំនួយ ម៉ាស និងបរិក្ខារវេជ្ជសាស្ត្រមួយចំនួនទៅបណ្តាប្រទេសជាមិត្ត ដូចជា ឡាវ ភូមា នេប៉ាល់ និងទីម័រ ជាដើម។ ជំនួយទាំងនេះជាការបង្ហាញនូវទឹកចិត្ត ស្រឡាញ់

[11] https://pressocm.gov.kh/archives/69579 (*គេហទំព័រទីស្តីការគណៈរដ្ឋមន្ត្រី*)

រាប់អាន និងជេះជួយគ្នាក្នុងគ្រាក្រ ដូចទៅនឹងពាក្យស្លោក ដែល**សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីបានលើកឡើងថា “*ជួយគ្នាក្នុងគ្រាក្រ ស្គាល់មិត្តល្អក្នុងគ្រាលំបាក*”។

ទស្សនវិស័យនេះ ក៏មិនឃ្លាតឆ្ងាយពីរឿងរាមកេរ្តិ៍ដែរ ដែលបានឆ្លុះបង្ហាញឆ្លើយតបទៅនឹងទិដ្ឋភាពនៃសង្គមកម្ពុជាយើងផងដែរ។ គួយ៉ាងនៅពេលដែលព្រះរាមករទ័ពទៅច្បាំងនឹងរាពណ៍ ព្រះរាមឈ្វេងយល់ថា ទ័ពរបស់ខ្លួននៅមានភាពតិចតួច ពុំអាចប្រយុទ្ធយកជ័យបាននោះឡើយ។ ព្រះរាមក៏បានស្នើសុំជួយយកអសាសុគ្រីព ក្នុងការសម្លាប់ពាលីដែលជាបង ដោយឱ្យហនុមានទៅចរចា។ នៅក្នុងលក្ខណ្ឌជួយគ្នាទៅវិញទៅមក បើសុគ្រីពព្រមជួយខ្លួនក្នុងការទៅប្រយុទ្ធនិងក្រុងរាពណ៍ ព្រះរាមនឹងជួយសម្លាប់ពាលី ហើយអភិសេកសុគ្រីពគ្រងរាជ្យនៅខខិនប៊ុរីដដែល។ នេះសឱ្យឃើញការចងសម្ពន្ធភាពរវាងគ្នាទៅវិញទៅមក ដើម្បីការបំពេញបំណង មហិច្ឆតារៀងខ្លួន។

| | | |
|---|---|---|
| ហនុមានថាបពិត្រអ្នកមាអើយ | អញខ្ញុំដឹងហើយ | សម្តេចពុំជឿចេស្តា។ |
| ព្រះបាទសម្តេចរាមា | រីអ្នកនេះណា | គឺអង្គព្រះនារាយណ៍ឯងហោង។*(ខ្សែ៥ ទំ.២២)* |

ម៉្យាងទៀត ព្រះរាមក៏បានប្រើយុទ្ធសាស្ត្រការទូតនេះ ជាមួយនឹងមហាជម្ពូដែរ។ ទ្រង់បានស្នើសុំទ័ពបន្ថែមពីមហាជម្ពូដោយឱ្យហនុមានទៅ។ ផ្ទុយទៅវិញ សិល្បៈនៃការទូតរបស់ព្រះអង្គមានភាពខ្លាំង ទ្រង់ឈ្វេងយល់ថា ហនុមានជាបុគ្គលមានចរិតឆេវឆាវ ឆាប់ខឹង ប្រសិនបើមហាជម្ពូមិនព្រមនោះនឹងអាចមានជម្លោះ ទើបទ្រង់ត្រាស់ឱ្យ អង្គទទៅជាមួយ ដើម្បីសម្រួលការ ចៀសវាងខូចប្រយោជន៍ជាដើម។

| | | |
|---|---|---|
| ជម្មតាអ្នកនាំរាជសារ | ពាក្យពេចន៍ធ្ងន់ | ស្រាលអត់អោនដោយធម៌សុចរិត។ |
| នឹងយោងយកគេជាមិត្ត | ល្អឹកគេឱ្យខុស | ក៏ឱ្យហនុមានអត់ហោង។ |
| គួរឱ្យអង្គទទៅផល | ទោះទោសធ្ងាំធ្ងង | គំនិតគំនាប់ខ្ជាប់ខ្ជួន។ |
| គាត់ចេះក្តីក្តាំស័ក្តិសួន | សក្តិសែងស្មើខ្លួន | នៃអង្គហនុមានស្នេហ៍ស្និទ្ធ។ *(ខ្សែ៧ ទំ.៩)* |

លើសពីនេះ នៅពេលដែលក្រុងរាពណ៍បានលួចយកសីតាជំបូង ព្រះរាមក៏បានធ្វើកំណត់ទូតតាមរយៈឯកអគ្គរាជទូតរបស់ខ្លួន គឺអង្គទ ឱ្យទៅប្រាប់រាពណ៍ប្រគល់នាងសីតាមកវិញ។ ក្នុងនាមខ្លួនជាមហាអំណាចមួយ មានភាពក្រអឺតក្រទម ថែមទាំងហ៊ានអុកឡុកក្នុងរោងជំនុំ ហើយបានរំឭកពីពាលីជាឪពុកបានប្រើឱ្យរាពណ៍យោលអង្រឹងឱ្យ ធ្វើឱ្យអាម៉ាសសព្វនាម៉ឺនមន្ត្រី។ លើសពីនេះអង្គទបានបានទះកំភ្លៀងរាពណ៍ដួលមុខមន្ត្រីទៀតផង។ មិនត្រឹមតែជាចំណាងការទូត តែអង្គទបានបំបាក់ស្មារតីក្រុងលង្កាឱ្យឃើញពីឫទ្ធានុភាពភាគីព្រះរាម។

| | | |
|---|---|---|
| ឲ្យជារាជទូតនាំសារ | ថ្កានលង្កាណា | នូវនាំសារសព្វវាទី។ |
| ត្រាស់ប្រើអង្គទក្របី | ថ្កើនរូវង្សី | ដ៏មានតេជៈជាញជ័យ។ |
| ចេះចាំអាថ៌អធ្យាស្រ័យ | សារពើអ្វីវៃ | ប្រកបលោកាស្តែង។*( ខ្សែ៩ ទំ.៤០-៤១)* |

### ២.១.២. វណ្ណៈសង្គម

ពិតណាស់គ្រប់សង្គមទាំងអស់តែងបែកចែកវណ្ណៈរបស់មនុស្សផ្សេងៗគ្នា។ គួយ៉ាងដូចក្នុងសង្គមឥណ្ឌាបុរាណគេបែងចែកវណ្ណៈជាបួន គឺវណ្ណៈព្រាហ្មណ៍ វណ្ណៈក្សត្រ វណ្ណៈវៃស្យៈ និងវណ្ណៈសូទ្រៈ។ ម៉្យាងទៀតគេក៏បានបន្ថែមវណ្ណៈមួយទៀតដែលគេចាត់ទុកថាជាវណ្ណៈថោកទាបនោះគឺ វណ្ណៈចណ្ឌាល។ រីឯបច្ចុប្បន្នគេឃើញមានវណ្ណៈពីរប៉ុណ្ណោះ គឺរវាងអ្នកមាននិងអ្នកក្រ ឬអ្នកមានអំណាច និងអ្នកគ្មានអំណាច។ ជាការពិតនៅក្នុងសង្គមដែលអ្នកមានអំណាចជិះជាន់អ្នកក្រខ្សត់ តូចតាចនោះ មុននឹង

ក្រោយគង់តែនឹងមានការបះបោរងើបប្រឆាំងមួយកើតឡើងជាមិនខាន។ វណ្ណៈពួកអភិជន តែងមើលងាយវណ្ណៈអ្នកអធនដែលជីវិតពួកគេពុំមានន័យ អាចទិញដូរដោយប្រើលុយកាក់បាន។

ជាក់ស្ដែងនៅក្នុងរឿងរាមកេរ្តិ៍ក៏បានផ្ដល់ជាទស្សនាទានសម្រាប់ថ្នាក់ដឹកនាំ សម្រាប់ជនានុជនទាំងអស់ត្រិះរិះពិចារណាចៀសវាងនូវការរើសអើង មើលងាយមើលថោក ដល់អ្នកតូចតាចជាងខ្លួន។ តួយ៉ាងនៅពេលដែលព្រះរាមបានយាងទៅរកនាងសីតា ទ្រង់ក៏បានជួបសត្វកុក។ សត្វកុកក្រោយពីបាននាងសីតាផ្ដែផ្ដាំ ខ្លួនក៏បានប្រាយប្រាប់ទៅកាន់ព្រះលក្ស្មណ៍ ព្រះរាម។ មិនថែមទាំងប៉ុណ្ណោះ កុកក៏បានស្ដីឱ្យអ្នកទាំងពីរដែលចាញ់កលយក្ស។ ព្រះរាមប្រុងនឹងយឹតធ្នូបាញ់ទៅកុក តែត្រូវបានកុកអង្វរវិញ។

កុកស្ដាប់ព្រះអនុជក្រោធឆ្លង ជៀលអាត្មាហោង ក៏សឹងវាចារឹងតេះ។
ហៃក្សត្រពីរឥតចំណេះ ម្ដេចឡើយមកតិះ នៃយើងជាជួសាមាន្យ។*(ខ្សែ៤ ទំ. ៣៣)*

ត្រង់នេះហើយដែលសបញ្ជាក់ឱ្យឃើញពីតឹកតាង ដែលក្នុងនាមជាអ្នកមានអំណាច ត្រូវចេះស្ដាប់មតិយោបល់អ្នកដទៃសិនមុននឹងសម្រេចចិត្តធ្វើអ្វីមួយ។ ម្យ៉ាងកាតព្វកិច្ចរបស់ព្រះអង្គ គួរដឹងគុណសត្វកុកដែលមានឧបការៈគុណចំពោះខ្លួនដែលបានបង្ហាញផ្លូវទៅរកនាងសីតា។ លើសពីនេះ វាជាគតិមួយក្នុងការពិចារណាថា ត្បិតមនុស្សមិនត្រូវមើលតែកំហុសរបស់អ្នកដទៃទេ ត្រូវឈ្វេងយល់ពីកំហុសរបស់ខ្លួន មិនត្រូវខ្លាចរអា តែគួរត្រងត្រាប់កែខៃជាបទពិសោធទៅវិញទើបល្អ។

ទន្ទឹមនឹងនេះ ចំណុចមួយទៀតដែលជាបញ្ហាទំនាស់នៃវណ្ណៈនោះ គឺទំនាស់រវាងក្រុងរាពណ៍និងពិភេកដែលជាប្អូន។ នៅក្នុងរោងជំនុំនៅពេលដែលក្រុងរាពណ៍បានសុំឱ្យពិភេកទស្សន៍ទាយពីជោគវាសនានគរ។ ពិភេកទូលឱ្យយកសីតាប្រគល់ឱ្យព្រះរាម បើពុំច្នោះ នោះនគរនឹងវិកវរមានកលិយុគបីដូចជាក្អែកនាំកែវស្ងួរ្យកាន្តមកទុកក្នុងសម្បុក ឆេះសម្បុកដូចនេះជាមិនខាន។ ផ្ទុយទៅវិញ ក្រុងរាពណ៍ពុំស្ដាប់នូវលទ្ធផលនៃការទស្សន៍ទាយនោះទេ ថែមទាំងជេរស្ដីពិភេកក្នុងរោងជំនុំ។ លើសពីនេះព្រះអង្គបានយកស្បែកជើងទៅវាយក្បាលពិភេកទៀតផង។ ទាំងនេះធ្វើឱ្យពិភេកមានភាពអាម៉ាសនាម៉ឺនមន្ត្រីដែលខ្លួនជាប្អូនផង ជាហោរាប្រចាំនគរទៀត ហើយត្រូវបានព្រះរៀមធ្វើបែបនេះ។

ទោះមឹងពុំចៀសលែងម- ន្ទិលទោសមឹងធ្ងន់ មាហជំអឹងព្រះអាជ្ញា។
អញទៅទរត្បូងមឹងនឹងក្រទា ដែកបែកសិរសា ដ៏ជាប្រាំពីរភាគផង។*(ខ្សែ៨ ទំ.៦)*

នេះហើយដែលជាកំហុសធ្ងន់មួយរបស់មេដឹកនាំពុំចេះស្ដាប់មន្ត្រីក្រោមឱវាទ ផ្ដល់ជាមតិ ទស្សនៈកែលម្អ។ ដោយសម្អាងតែខ្លួនមានអំណាច ឋានៈខ្ពស់ ពុំចាំបាច់សួរនាំច្រើន។ មិនត្រឹមថែមប៉ុណ្ណោះថែមទាំង ជេរស្ដីមន្ត្រីក្រោមឱវាទនាំឱ្យបាត់បង់ធនធានមនុស្សល្អៗទៅ។ ការគិតដោយអត្តានិយម គំនិតអញនិយមមិនទទួលយកគំនិតអ្នកដទៃនេះ អាចនឹងនាំទុក្ខដល់ខ្លួនទៀតផង បីដូចសុភាសិតខ្មែរលើកឡើងថា “**ដើរឱ្យមានបី ស្រដីឱ្យមានប្អូន**”។

## ២.១.៣. យុទ្ធសាស្ត្រសង្គ្រាម

រឿងរាមកេរ្តិ៍ក៏មិនខុសពីរឿងសាមកុកដែលជាក្បួនពិជ័យសង្គ្រាមមួយដ៏វិសេសវិសាល។ តែប្លែកត្រង់ថា រឿងសាមកុកបង្ហាញពីសង្គមមនុស្សពិតជាក់ស្ដែង រីឯរឿងរាមកេរ្តិ៍បានបង្ហាញពីតួអង្គនីយកម្ម ជានិមិត្តរូប តែបានបកអាក្រាតនូវទិដ្ឋភាពនៃក្បួនសឹកសង្គ្រាមមួយដែលនាំឱ្យបានជ័យជម្នះ។

### ក. សង្គ្រាមចិត្តសាស្ត្រ

ការធ្វើសឹកសង្គ្រាមទាមទារឱ្យមេដឹកនាំមានគំនិតវៃឆ្លាត មានល្បិចកល និងភាពបត់បែនខ្ពស់ក្នុងការកម្ចាត់សត្រូវឬ ដៃគូរបស់ខ្លួន។ ការធ្វើសង្គ្រាមនេះ មិនមែនតែជាការប្រឈមមុខដាក់គ្នាលើតែកម្លាំងនោះ តែវាទាមទារការប្រើប្រាជ្ញាក្នុងការប្រយុទ្ធផងដែរ។

ជាក់ស្តែងនៅក្នុងរឿងរាមកេរ្តិ៍ ក៏បានលើកយកយុទ្ធសាស្ត្រនៃការបំបាក់ស្មារតីនេះមកបង្ហាញផងដែរ។ ជាក់ស្តែងតាមរយៈខ្សែរឿងយើងឃើញថា នៅពេលធ្វើសង្គ្រាមជាមួយព្រះរាម ក្រុងរាពណ៍បានប្រើល្បិចបោកបញ្ឆោតដោយប្រើក្មួយរបស់ខ្លួននាងបុញ្ញកាយ ជាកូនរបស់ពិភេកនោះ ឱ្យកាឡាខ្លួនជានាងសីតាស្លាប់ ដោយអណ្តែតទឹកទៅជិតព្រះពន្លារបស់ព្រះរាម។ ការបំបាក់ស្មារតី គឺចង់ឱ្យព្រះរាមឈឺចិត្ត ដោយហេតុដឹងថានាងសីតាបានស្លាប់ហើយ ខ្លួនត្រូវដកថយទ័ពទៅវិញ។ ប៉ុន្តែការណ៍នេះមិនបានធ្វើឱ្យព្រះរាមខ្លាចនោះទេ នៅពេលព្រះអង្គដឹងថានាងបុញ្ញកាយជាកូនរបស់ពិភេក ក៏ដោះលែងនាងទៅវិញ។ ជាមួយគ្នានេះរាពណ៍ក៏បានប្រើយុទ្ធសាស្ត្រដដែល ដែលប្រើឱ្យក្មួយស្រីខ្លួន គឺនាងសុកាថា កាឡាខ្លួនជានាងសីតាទៅធ្វើសង្គ្រាមជាមួយកុម្ភណ្ឌ ដោយបញ្ឆោតថា នាងសីតានឹងត្រូវស្លាប់។ ពាក្យរបស់កុម្ភណ្ឌនេះបានធ្វើឱ្យព្រះលក្ស្មណ៍បាក់អារម្មណ៍លែងចង់ប្រយុទ្ធ។

លើសពីនេះ ក្រុងរាពណ៍ក៏បាននាំនាងសីតាជិះលើរាជរថហោះមកបញ្ឈឺព្រះរាមនៅមុខព្រះពន្លា។ ព្រះរាមបានសួរពិភេកអំពីដើមហេតុ ទើបពិភេកបញ្ជាក់ថា នាងនោះជានាងសីតា ព្រះរាមក៏បានផ្លែងសរបាក់រាជរថនោះ។ ការធ្វើទុកបុកម្នេញរបស់រាពណ៍មិនទាន់បញ្ចប់នៅឡើយទេ ទ្រង់បានហៅពិស្ណុការមកជួយសាងរាជរថថ្មី។ ការបញ្ឈឺម្តងនេះធ្វើឱ្យព្រះរាមចង់ផ្លែងសរព្រហ្មាសដើម្បីស្លាប់រាពណ៍ តែត្រូវបានពិភេកនិងព្រះលក្ស្មណ៍ឃាត់ ត្បិតចំហាយសរនេះអាចប៉ះពាល់ដល់នាងសីតា។ ទើបទ្រង់សម្រេចចិត្តប្រើចង្អុលទិព្វ ធ្វើឱ្យរាពណ៍ចុកពោះទៅ។

| | | |
|---|---|---|
| ព្រះដណ្តឹងពិភេកហោរា | ហៃពិភេកបា | អ្វីសោតសន្ទៅមកនោះ។ |
| ពិភេកបង្គំទូលឆ្លោះ | នារាជរថនោះ | គឺអង្គឥសូររាពណា។ |
| ឯក្រោយរាជរថនោះណា | គឺព្រះសីតា | មហាមហេសីថ្លៃ។ |
| ព្រះអង្គខ្ញាល់ព្រះហឫទ័យ | ទ្រង់ព្រះក្រោធក្រៃ | អសូរចិត្តទ្រើសមហិមា។ *(ខ្សែ៨ ទំ. ៣៥)* |

**ខ. យុទ្ធសាស្ត្រផ្តាច់ស្បៀង**

ស្បៀងអាហារពិតជាសំខាន់សម្រាប់ការរស់នៅ ពិសេសក្នុងការធ្វើសង្គ្រាម។ កម្លាំងនៃការធ្វើសង្គ្រាមបានជោគជ័យក៏មកពីកងទ័ពមានអាហារផ្គត់ផ្គង់គ្រប់គ្រាន់ផងដែរ។ ហេតុដល់មានពាក្យចាស់លោកពោលឡើងថា "**ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ**" ដែលសឱ្យឃើញពីសារៈសំខាន់នៃការគ្រប់គ្រងស្បៀងអាហារសម្រាប់សឹកសង្គ្រាម។

តួយ៉ាងនៅក្នុងរឿងរាមកេរ្តិ៍ នៅពេលក្រោយពិភេកចេញពីនគរ រាពណ៍បានឈ្វេងយល់ពីមូលដ្ឋានទ័ពរបស់ព្រះរាមគឺភាគច្រើនជាពានរ។ រាពណ៍បានប្រើឱ្យរុក្ខសេន និងពលយក្សទៅទៅយាមព្រៃកុំឱ្យពួកពលស្វាមកបេះបាន។ ពេលព្រះរាមប្រើសេនាឱ្យទៅបេះផ្លែឈើ ក៏បានជួបនឹងរុក្ខសេន។ រុក្ខៈខាងទ័ពស្វាបានប្រយុទ្ធនឹងរុក្ខសេនរហូតទាល់តែស្លាប់រៀងៗខ្លួន។ ត្រង់នេះអាចបញ្ជាក់ឱ្យឃើញពីទង្វើរបស់ក្រុងរាពណ៍ដែលយល់ពីក្បួនសឹកដ៏សំខាន់ក្នុងការបំបាក់ទ័ពរបស់ព្រះរាមដោយវិធីសាស្ត្រផ្តាច់ស្បៀង ព្រោះបើទ័ពព្រះរាមពុំមានស្បៀងទេ រាពណ៍នឹងងាយទទួលបានជ័យជម្នះ។

| | | |
|---|---|---|
| អញនូវឱ្យយក្សកៀរគោះ | គ្នាចាំព្រៃនោះ | ដោយសព្វអន្លើភ្លាត់ចាប់។ |
| ចូលព្រៃយក្សយើងបីសម្លាប់ | រត់ថយទៅទ័ព | ក៏ស្លាប់នឹងដាច់ពោះឯង។ |
| ទោះបីរស់សឹងដ៏ស្គមធោងធេង | ព្រមព្រួយចិត្តឯង | រំពៃរំពឹងរឹងរិល។ *(ខ្សែ៩ ទំ.១៩)* |

**គ. នយោបាយឈ្នះ-ឈ្នះ**

បើយើងនិយាយពី នយោបាយឈ្នះ-ឈ្នះនេះ គ្រប់គ្នារមែងដឹងពីប្រវត្តិរូបបុគ្គលមួយរូបដែលជាតួអង្គសំខាន់ក្នុងការដឹកនាំនយោបាយនេះសម្រាប់កម្ពុជានោះ គឺ **សម្តេចតេជោ ហ៊ុនសែន**។ គោលការណ៍ដ៏សំខាន់នៃនៃនយោបាយឈ្នះ-ឈ្នះនេះ គឺលោកមានប្រសាសន៍ថា៖ ចំណុចទី ១ ការធានាអាយុជីវិត និងរូបកាយ, ចំណុចទី ២ គឺធានាអាជីព និងមុខរបរ ក៏ជាចំណុចដ៏

មានសារសំខាន់ខ្លាំងណាស់, ចំណុចទី ៣ នៃនយោបាយឈ្នះឈ្នះ គឺការធានាកម្មសិទ្ធិ ទាំងចលនទ្រព្យ និងអចលនទ្រព្យ។[12] ជាការពិតណាស់ចំណុចទាំងនេះហើយដែលធ្វើឱ្យកម្ពុជាជាផ្លុងមួយ មានការអភិវឌ្ឍ វឌ្ឍនភាពជាតិជាដើម។

មិនខុសគ្នានេះដែរ គន្លងយុទ្ធសាស្ត្រក្នុងការដឹកនាំ កសាងនូវគោលនយោបាយឈ្នះ-ឈ្នះ ក៏បានប្រតិដ្ឋឡើងក្នុងរឿងរាមកេរ្តិ៍ដែលមានអាយុកាលរាប់សតវត្សរ៍មុនគ.ស.ទៀតផង។ ក្រោយពេលដែលក្រុងរាពណ៍ជាបងបានដេរស្តី វាយក្បាលនឹងស្បែកជើងទៀតផងនោះ ពិភេក ដែលជាហោរាកំពូលក្នុងក្រុងលង្កានោះត្រូវបានចាកចេញមកសុំចុះចូលជាមួយព្រះរាម។ ព្រះរាមក៏យល់ព្រមឱ្យពិភេកមួយចូលជួយខ្លួនក្នុងសង្គ្រាមជាមួយលង្កា។ ដោយរក្សាតំណែងពិភេកជាហោរាដដែល។ លើសពីនេះពេលសម្លាប់រាពណ៍និងទទួលបានសីតាមកវិញហើយ ព្រះរាមបានឱ្យពិភេក គ្រប់គ្រងនៅនគរលង្កាវិញ ជាការលើកទឹកចិត្តទៀតផង។ ត្រង់នេះសឱ្យឃើញពីយុទ្ធសាស្ត្ររបស់ព្រះរាមដែលទទួលយកអតីតគូបដិបក្ខរបស់ខ្លួនមករួមរស់ជាកម្លាំងមួយរបស់ខ្លួន។ លើសពីនេះព្រះរាមបានដឹងពីទេពកោសល្យរបស់ពិភេករួចស្រេចទៅហើយទើបទ្រង់កាន់តែទុកចិត្ត ហើយបន្តនូវតំណែងរបស់ពិភេកដដែល ដោយមិនមានការរើសអើង។

ក្នុងន័យនេះការរួបរួមក្នុងសង្គមមួយជាភាពចាំបាច់បំផុតដែលជាការកសាងនូវកម្លាំងមួយដ៏រឹងមាំ។ តួអង្គព្រះរាមបានយល់ច្បាស់ពីក្បួនសឹក ដោយលើកទឹកចិត្តនិងជំរុញយកដៃគូសត្រូវរបស់ខ្លួនមកជាចំណុះ តួយ៉ាងដូចជាការឱ្យពិភេកទៅបញ្ចុះបញ្ចូលកុម្ភកាណ៍មកដូច្នេះដែរ។ ទិដ្ឋភាពនៃផ្នត់គំនិតនេះក៏ស្ថិតនៅជាទស្សនាទានមួយសម្រាប់សង្គម ដូចនៅក្នុងទសវត្សរ៍ទៅ៨០ កម្ពុជាត្រូវបានបែងជា៤តំបន់ធំៗ។ ក្រោយការអនុវត្តនយោបាយឈ្នះ-ឈ្នះ យើងមានខ្មែរតែមួយ រដ្ឋាភិបាលតែមួយនិង ព្រះមហាក្សត្រតែមួយ ដោយមិនឱ្យខ្មែរណាមួយចាញ់ ឬបាត់បង់អ្វីនោះទេ។

### ២.២. តម្លៃអក្សរសិល្ប៍នៃរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរឆ្លុះបញ្ចាំងតាមរយៈវប្បធម៌

តម្លៃនៃរឿងរាមកេរ្តិ៍បានឆ្លុះបញ្ចាំងជាលក្ខណៈអរូបីក្រោមទម្រង់ជាទស្សនាទាន ចក្ខុវិស័យជាដើមនៅក្នុងទិដ្ឋភាពសង្គមធម៌។ បន្តទៅទៀតនេះយើងនឹងពិនិត្យមើលនៃឥទ្ធិពលនៃរឿងរាមកេរ្តិ៍តាមរយៈវិស័យវប្បធម៌ ដែលមានលក្ខណៈរូបី អាចឃើញ អាចយល់បាន ឬអាចប៉ះកាន់បានទៀត។ រឿងរាមកេរ្តិ៍នេះបានជ្រៀតចូលទៅក្នុងផ្នត់គំនិតនៃជនជាតិខ្មែរតាំងពីព្រះមហាក្សត្រ ដល់ប្រជានុរាស្ត្រ ដែលបានស្រឡាញ់រាប់អាន ហើយបានបញ្ចូលវាទៅផ្នែកផ្សេងៗនៃវប្បធម៌ទៀតផង។

### ២.២.១. ជំនឿ

#### ក. ជំនឿលើហោរា

មនុស្សខ្មែរភាគច្រើនមានជំនឿទៅលើការទស្សន៍ទាយយ៉ាងខ្លាំងទោះតិចឬច្រើនក្តី ដូចជាការទស្សន៍ទាយមើលគូស្រករ មើលរាសី មើលថ្ងៃខែឆ្នាំល្អក្នុងការធ្វើអ្វីមួយ ការចាក់គម្ពីរចង់ដឹងពីជោគវាសនារបស់ខ្លួនទៅថ្ងៃអនាគត ការធ្វើរឿងទាំងនេះនៅតែមិនអាចចោលបាន បើទោះបីជាប្រទេសជាតិមានការរីកចម្រើនដល់កម្រិតណាក៏ដោយ។ ការជាប់ការទាក់ទងទៅនឹងការទស្សន៍ទាយនៃរឿងរាមកេរ្តិ៍ គឺបានបង្ហាញតាមរយៈទំនៀមទម្លាប់នៃការចាក់គម្ពីរគឺការទស្សន៍ទាយអំពីជោគជតារាសី មានន័យថាដូនតាខ្មែរយើងបានយកសកម្មភាព ឬដំណើរជីវិតរបស់តួអង្គក្នុងរឿងរាមកេរ្តិ៍ មកធ្វើជាការទស្សន៍ទាយពីដំណើរជីវិត និងព្រេងវាសនារបស់មនុស្ស។ តាមក្បួនតម្រាទស្សន៍ទាយបើគេចង់ដឹងពីគ្រោះនិងជោគជតារបស់បុគ្គលណាម្នាក់យ៉ាងណានោះ គេឱ្យមើលតម្រាធត្របីជាន់ បើគេរាប់អាយុរបស់បុគ្គលដែលចង់ដឹងពីជោគជាតាមានអាយុប៉ុន្មាន គេឱ្យដកមួយឆ្នាំចេញ បើប្រុសឱ្យរាប់ចាប់ពីព្រះ

[12] *ប្រសាសន៍សម្តេចតេជោ ហ៊ុនសែន នាថ្ងៃ៣០ វិច្ឆិកា ២០១៨ ខួប២០ ឆ្នាំនៃនយោបាយឈ្នះ-ឈ្នះ* https://pressocm.gov.kh/archives/46314 (*ទីស្តីការគណៈរដ្ឋមន្ត្រី*)

រាមទៅពិម្ពិសារ បើស្រីឱ្យរាប់ចាប់ពីសីតាទៅជាតាយុ រាប់ចាប់ពី១ឆ្នាំរហូតទល់នឹងអាយុរបស់បុគ្គលនោះ គឺដល់ខ្ទង់ណា លេខណា ចូរទាយតាមស្ថាននុះចុះ។

ម្យ៉ាងទៀតនៅក្នុងការទស្សន៍ទាយ គេបានយកតួអង្គក្នុងរឿងមកធ្វើជាតំណាងក្នុងការទាយរបស់គេដែរ ដូចជា តួអង្គព្រះរាម នាងសីតា ទសកណ្ឋ ពិភេក ហនុមាន ជតាយុ មកប្រើរាប់បូកគិតនិងថ្ងៃផងដែរ [13]។

ឧទាហរណ៍៖

- អាទិត្យក្នុងខ្លួនឥសាន ពិភេក យុនមារ ត្រូវចាកចេញក្រុងលង្កា ទាយថា *គ្រោះកាចណាស់ណាពួកងពង្សញាតិការនឹងមកពាសពានដាក់ខ្លួន និងព្រាត់ប្តីកូន ទុក្ខក្តៅស្ងំស្ងួន និងពានអាប់យសពុំល្អមួយទៀត នឹងឃ្លាតចាកស្ថាន ទោសទណ្ឌសាមាន្យនឹងធ្លាក់ត្រូវត្រង់អាត្មា៤ខែ ប្រយ័ត្នកាយាក្រែងជួនប៉ះពារនឹងរាជអាជ្ញានោះហោង។*

ជាមួយគ្នានេះនៅពេលដែលក្រុងរាពណ៍ ផ្តើមធ្វើសង្គ្រាមនឹងព្រះរាម ក្រុងរាពណ៍បានឱ្យពិភេកជាប្អូនទស្សន៍ទាយអំពីជោគវាសនានៃក្រុងលង្កា និងពីការធ្វើសង្គ្រាមរបស់ខ្លួនថា តើអាចយកជ័យជម្នះឈ្នះព្រះរាមបានអត់? ពិភេកបានទស្សន៍ទាយថា ការធ្វើសង្គ្រាមរបស់ក្រុងរាពណ៍ជាមួយនឹងព្រះរាម គឺក្រុងរាពណ៍នឹងបរាជ័យ ហើយក្រុងលង្កានឹងទទួលរងនូវក្តីវិនាសអន្តរាយ។ ពិភេកបានសូមឱ្យក្រុងរាពណ៍ប្រគល់នាងសីតាទៅព្រះរាមវិញ នោះទើបអ្វីៗនឹងល្អប្រសើរឡើងវិញ ប៉ុន្តែការទាយរបស់ពិភេកធ្វើឱ្យក្រុងយក្សខឹងយ៉ាងខ្លាំង និងមិនស្តាប់ការអង្វររបស់ពិភេកទេ ហើយថែមទាំងប្រមាថតិះដៀលពិភេកនៅចំណោមមុខមន្ត្រីទាំងអស់ ដែលធ្វើឱ្យពិភេកអន់ចិត្តនឹងការមើលងាយនេះ បន្ទាប់មកពិភេកក៏រត់ទៅចុះចូលនឹងព្រះរាម។

**ខ. ជំនឿលើពាក្យបណ្តាសា**

ពាក្យថា "បណ្តាសា" នៅក្នុងនិយមន័យរបស់វចនានុក្រមខ្មែរសម្តេចសង្ឃរាជ ជួន ណាត បានសេចក្តីថា *ពាក្យផ្តន្ទា ពាក្យជេរប្រទេច ពាក្យសំបូងសង្រ្វូងឱ្យគេវិនាសហិនហោច* [14]។ ចំពោះការបណ្តាសានេះ កើតឡើងបានដោយសារជម្លោះរវាងភាគីពីរឬច្រើន ដែលសមាសភាពគឺអ្នកដាក់បណ្តាសា និងអ្នកត្រូវបានគេដាក់បណ្តាសា។ ការដាក់បណ្តាសាគឺមានតាំងពីសម័យបុរាណមកម្ល៉េះ គេចាត់ទុកជាជំនឿមួយយ៉ាងមុតមាំហើយនៅតែមិនសាបរលាបរហូតមកដល់បច្ចុប្បន្ន។របៀបនៃការដាក់បណ្តាសារបស់ខ្មែរ គឺការអុជធូបរួចហើយបួងសង្រ្វូងរៀបរាប់ពាក្យនូវអ្វីដែលគេត្រូវការឱ្យភាគីម្ខាងវិនាសអន្តរាយ ហើយជួនកាលគេថែមទាំងដុតអំបិល ដុតប្រហុក ដែលជានិមិត្តរូបការការដាក់បណ្តាសានេះទៅតាមកំហឹងរបស់គេ។ ហើយគេជឿជាក់ថា ការបួងសង្រ្វូង ជេរប្រទេច ផ្តន្ទានេះនឹងស័ក្តិសិទ្ធិដូចអ្វីដែលគេចង់បាន។

ជាក់ស្តែងរឿងរាមកេរ្តិ៍ខ្មែរ បានបង្ហាញពីការដាក់បណ្តាសា និងការទទួលរងនូវបណ្តាសាតាមរយៈតួអង្គជាអាទិទេពតួអង្គមនុស្ស និងតួអង្គសត្វផងដែរ។ ជាក់ស្តែងនៅក្នុងការនិទានរឿងរាមកេរ្តិ៍របស់តាចក់ បានបង្ហាញពីការទទួលរងបណ្តាសារបស់តួអង្គម្តាយហនុមានឈ្មោះនាងសុខពីម្តាយរបស់នាង។ នាងសុខត្រូវម្តាយដាក់បណ្តាសា ដោយសារតែនាងបានប្រាប់រឿងផិតក្បត់របស់ម្តាយទៅឪពុក ធ្វើឱ្យម្តាយនាងខឹងយ៉ាងខ្លាំង ហើយបានជេរប្រទេចបណ្តាសានាងថា បើនាងសុខដាក់គូទត្រង់ណាឱ្យជាប់គូទត្រង់នោះ។ ការជេរប្រទេចផ្តន្ទានេះពិតជាស័ក្តិសិទ្ធិមែន គឺនាងសុខបានជាប់គូទនឹងថ្មដូចការដាក់បណ្តាសារបស់ម្តាយនាងមែន។ ចំណែកឯតួអង្គពាលី ដែលជាតួអង្គខ្លាំងពូកែម្នាក់សូម្បីតែក្រុងរាពណ៍ក៏ខ្លាចដែរតែត្រូវស្លាប់ដោយសរព្រហ្មាស្ររបស់ព្រះរាម ហើយការស្លាប់នេះក៏ទាក់ទងនឹងបណ្តាសាដែរ គឺនាងតារាទេពី ដែលជាមហេសីរបស់ពាលី ដោយកាលមុននៅនាទេវលោកជាភរិយារបស់សុគ្រីព ប៉ុន្តែត្រូវពាលីបំពារបំពានលើរូបកាយ ទើបព្រះឥសូរដាក់បណ្តាសាពាលី ឱ្យស្លាប់នឹងសរព្រហ្មាស្ររបស់ព្រះ

---

[13] *ព្រហ្មជាតិ (កណ្ឌទី២)* J.S.R.C. KHAO.I.DANG. MARCH,1991 ទំ.១០៧

[14] *ជួន ណាត, វចនានុក្រមខ្មែរភាគ១ ភាគ២, ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៨, ទំ.៥៤១*

ស្ត្រី រួចទ្រង់បណ្ដេញចុះពីឋានសួរមក [15]។

ពិតណាស់អក្សរសិល្ប៍រឿងរាមកេរ្តិ៍ មានបង្ហាញពីការដាក់បណ្ដាសាជាច្រើននៅក្នុងដំណើររឿង ហើយយើងក៏ដឹងហើយថាអក្សរសិល្ប៍វាបានជះឥទ្ធិពលទៅដល់ផ្នត់គំនិតការរស់នៅមនុស្សនៅក្នុងសង្គមផងដែរ ដូចគ្នាដែររឿងរាមកេរ្តិ៍គឺជារឿងមួយដែលជះឥទ្ធិពលយ៉ាងខ្លាំងចំពោះសង្គមខ្មែរយើងតាំងពីយូរណាស់មកហើយ។ ដូច្នេះយើងអាចគិតបានថា ប្រជាជនខ្មែរយើងមានទម្លាប់នៃការដាក់បណ្ដាសាតាមរយៈឥទ្ធិពលអក្សរសិល្ប៍នេះឯង។

**គ. ជំនឿលើសត្វ**

ជំនឿតូតឹមនិយមជាការជឿលើសត្វដែលជាដើមដំបូងនៃសន្តិវង្សជាអាទិទេព ជាអវតារបស់ អាទិទេព ជាអ្នកនាំសាររវាងមនុស្សនិងអាទិទេព ជាភាវៈមានអំណាចស័ក្តិសិទ្ធដែលគួរគោរពបូជា ជាភាវៈនាំមកនូវប្រផ្នូលល្អឬអាក្រក់ជាដើម។ [16] នៅត្រង់ចំណុចនេះ សត្វត្រូវបានគេចែកជា បីប្រភេទ ធំៗគឺ ទីមួយសត្វអច្ឆរិយដែលមាននៅក្នុងទេវកថាឬគម្ពីរសាសនា ទីពីរជាសត្វដែលអ្នកស្រុកបាន ផ្សាំ ឬចិញ្ចឹមសម្រាប់យកសាច់បរិភោគ និង ទីបី ជាសត្វព្រៃ។ ប្រភេទសត្វទាំងបីនេះយើងឃើញមានតាមរយៈរឿងព្រេងនិទាន ចម្លាក់នៅលើប្រាសាទ គំនូរតាមវិហារ វត្តអារាមជាដើមវាបានស្ថិតនៅក្នុងផ្នត់គំនិតខ្មែរដែលស្ដែងឱ្យឃើញពីជំនឿខ្មែរតាំងពីបូរាណកាលមក។ កាលគេលើកយកសត្វមក ឆ្លាក់ គូរ ឬនិទាននេះមិនមែនជាភាពចៃដន្យនោះឡើយ។ បុព្វបុរសខ្មែរបានយល់ច្បាស់អំពី ទិដ្ឋភាពជំនឿ និង ប្រផ្នូលនៃសត្វទាំងនោះ អស់រួចជាស្រេច។

ការកត់សម្គាល់របស់ប្រជាជនខ្មែរតាំងពីបុរាណមក ទាក់ទងនឹងឥទ្ធិពលរបស់សត្វដែលជាប្រផ្នូលនាំឱ្យកើតមាននូវរឿងអ្វីមួយនៅពេលដែលគេជួបសត្វនោះ។ ចំពោះរឿងនេះដែរនៅក្នុងរឿងរាមកេរ្តិ៍ ក៏បានបង្ហាញពីសត្វមួយចំនួន ដោយគេគិតថាជាសត្វនាំចង្រៃ ហើយខ្មែរយើងក៏បានចាត់ទុកថាសត្វនេះជាសត្វអពមង្គលដែរ នោះគឺសត្វក្អែក និងសត្វកុក។ នៅសេចក្ដីផ្ដើមនៃរឿងរាមកេរ្តិ៍ បានបង្ហាញពីយក្សមួយបានកាឡាខ្លួនជាសត្វក្អែក មកចឹកហោមពិធីរបស់ឥសីពិស្វាមិត្រដែលជាគ្រូរបស់ព្រះរាមនិងព្រះលក្ស្មណ៍ បណ្ដាលឱ្យឥសីខឹងយ៉ាងខ្លាំង ហើយបង្គាប់ឱ្យព្រះរាមផ្លែងសរសម្លាប់ក្អែកកាឡាស្លាប់នៅពេលនោះទៅ។ ចំណែកឯសត្វកុក នៅក្នុងរឿងរាមកេរ្តិ៍ត្រូវបានគេកំណត់ជាស្រេចថា ជាសត្វនាំចង្រៃ។ នៅក្នុងដំណើររឿង ពេលនាងសីតាត្រូវក្រុងរាពណ៍ចាប់យកទៅ ហើយនៅតាមផ្លូវសីតាបានជួបនឹងសត្វកុករួចក៏ផ្ដាំផ្ញើឱ្យកុកនាំដំណឹងនៃការចាប់ខ្លួននេះ ទៅប្រាប់ព្រះរាមផង។ កុកក៏យល់ព្រម នៅពេលជួបព្រះរាមព្រះលក្ស្មណ៍ កុកក៏រៀបរាប់តាមដំណើររឿងដែលខ្លួនបានជួបនឹងនាងសីតា ប៉ុន្តែនៅពេលនោះបែរជាព្រះលក្ស្មណ៍ខឹងសត្វកុកយ៉ាងខ្លាំង ថែមទាំងចង់សម្លាប់ផ្ដាច់ជីវិតទៀតផង។ នៅត្រង់នេះគេចង់បញ្ជាក់ថា ព្រះលក្ស្មណ៍ខឹងនឹងសត្វកុក ព្រោះគិតថាជាសត្វនាំនូវរឿងអពមង្គល សត្វចង្រៃ គឺឱ្យតែរឿងអ្វីក៏ដោយចេញពីមាត់របស់សត្វគឺសុទ្ធតែចង្រៃឧបទ្រពអពមង្គលទាំងអស់ ទើបព្រះរាម ព្រះលក្ស្មណ៍មិនចង់ដឹងដំណឹងអ្វីពីសត្វកុកឡើយ។

នៅក្នុងជំនឿខ្មែរ សត្វទាំងពីរនេះត្រូវបានប្រជាជនខ្មែរ មានជំនឿដោយកត់សម្គាល់ដូចតទៅ៖

សត្វក្អែក បើកាលណាអ្នកណាម្នាក់នៅក្នុងផ្ទះ ទៅនៅស្រុកឆ្ងាយ បើសិនជាក្អែកបូលនៅជិតខាង ហើយមុខរបស់វាបែរទៅរកអ្នកដែលអវត្តមាននោះ វានឹងបញ្ជាក់ថាអ្នកនោះនឹងត្រឡប់មកវិញឆាប់ៗ។ ប៉ុន្តែបើសិនជាក្អែកបូលបែរមុខទៅទិសផ្សេងនោះគឺវាបញ្ជាក់ពីទុក្ខព្រួយ។ ចំណែកឯសុភាសិតខ្មែរមួយបានពោលថា “**ពងមាន់កុំផ្ញើនឹងក្អែក**” ព្រោះក្អែកចូលចិត្តពងមាន់ណាស់ដែលមានន័យជាអត្ថាបដិរូបបានសេចក្ដីថា កុំប្រគល់ស្រីក្រមុំឱ្យប្រុសកំលោះ[17]។

---

15 *លាង ហាប់អាន,សិក្សាអត្ថបទរឿងរាមកេរ្តិ៍, ១៩៩៩(វាយឡើងវិញ) ទំ.៣៥*

16 *ប៉ាន់ វុត្ថា, គ្រឹះទស្សនវិជ្ជាខ្មែរ, និក្ខេបបទ,រាជបណ្ឌិត្យសភា, ២០១៣, ទំ ៧០*

17 *ឈិន យូន, ជំនឿផ្សេងៗនៃជនជាតិខ្មែរ,បណ្ណាគារ អប្សរា,១៩៩៩, ទំ.២៦*

រីឯសត្វកុកវិញ ខ្មែរយើងតែមានជំនឿថាបើសិនជាមានសត្វកុកមកទំលើដំបូលផ្ទះនឹងមានប្រផ្នូលមិនល្អ គឺនឹងត្រូវសមាជិកក្នុងគ្រួសារមានជំងឺធ្ងន់ធ្ងរ ដោយគេគិតថាសត្វកុកជាសត្វមួយប្រភេទមិនចេះទំលើអ្វីនោះទេសូម្បីតែមែកឈើតែបើវាទំគេគិតថាជាហេតុភេទមិនល្អ ហើយបើទំនៅលើដំបូលផ្ទះទៀតគឺចង្រៃខ្លាំងណាស់។

**ឃ. ជំនឿលើយ័ន្តមន្តអាគមគាថា**

នៅក្នុងជំនឿខ្មែរ ការជឿទៅលើយ័ន្តគាថា នៅតែមានឥទ្ធិពលមកដល់បច្ចុប្បន្ន។ យ័ន្ត គឺជាវត្ថុមួយដែលមានការចារសូត្រមន្តអាគម ធ្វើនៅលើក្រដាស ឬលោហៈធាតុ។ វាត្រូវបានគេជឿថា ជារបស់ការពារខ្លួនពីសត្រូវ ដែលតាមយាយីក្នុងផ្លូវមន្តអាគម (ផ្លូវងងឹត) និងជាវត្ថុសក្តិសិទ្ធិក្នុងការការពារខ្លួនពីគ្រោះចង្រៃផ្សេងៗ។ ចំពោះឥទ្ធិពលរឿងរាមកេរ្តិ៍ នៅក្នុងជំនឿយ័ន្តគាថានេះដែរ យើងឃើញថានៅក្នុងរូបយ័ន្ត ដែលគេបានចារនោះ គឺមានរូបតួអង្គនៃរឿងរាមកេរ្តិ៍។ ឧទាហរណ៍៖ រូបហនុមានក៏ជាតំណាងក្នុងការការពារឧបទ្រពចង្រៃផងដែរ ព្រោះយើងឃើញមានចម្លាក់រូបហនុមាននៅលើសន្លឹកមាសស្ពើង ដែលបុព្វបុរសខ្មែរប្រើជាយ័ន្តអាថាន់ ដើម្បីការពារទប់ទល់នឹងឧបទ្រពចង្រៃ។

**ង. ជំនឿលើអ្នកតា**

ពិតណាស់ថារឿងរាមកេរ្តិ៍នេះ បានជ្រៀតចូលសរសៃនៃដួងវិញ្ញាណរបស់ប្រជាជនខ្មែរតាំងពីសម័យដើមរៀងមក។ ពីតួអង្គនៃអក្សរសិល្ប៍ វីរកថា បានក្លាយជាតួអង្គនៃអ្នកតាក្នុងសង្គមខ្មែរ។ តួអង្គមួយចំនួនក្នុងរឿងរាមកេរ្តិ៍បានក្លាយអ្នកតា ដែលប្រជាពលរដ្ឋមានជំនឿនិងគោរពបូជា។

ជាក់ស្តែងដូចជា អ្នកតាកំហែងហនុមាននៅវត្តស្វាយអណ្តែត ស្រុកល្វាឯម ខេត្តកណ្តាល។ គួរបញ្ជាក់ផងដែរថា វត្តនេះជាទីកន្លែងមួយដែលបង្កើតវង់ល្ខោនខោលវត្តស្វាយអណ្តែត ហើយត្រូវ **ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិមុនីវង្ស កុសមៈនារីរ័ត្ន សេរីវឌ្ឍនា** នាសម័យនោះ ប្រោសព្រះរាជប្រទានឱ្យចូលសម្តែងនៅក្នុងពិធីតាំងតុក្នុងព្រះបរមរាជវាំង ។ ថ្មីៗនេះល្ខោនខោលត្រូវបានចូលជាបេតិកភណ្ឌអរូបីពិភពលោកផងដែរ។

លើសពីនេះ នៅវត្តកៀនស្វាយក្រៅមានគេមកសង់អាគារមួយដែលគេហៅថា “ប្រាសាទ” នៅទីកន្លែងរោងទសមុខចាស់ ហើយដាក់ឈ្មោះថា “ប្រាសាទលោកតាទស្សបារមីមុខដប់” ដែលមនុស្សតែងមកធ្វើបុណ្យបន់ស្រន់។ រីឯវត្តស្វាយអណ្តែតនៅត្រើយម្ខាង កាលពីមុនបាក់ច្រាំងទន្លេ មានខ្ទមអ្នកតាមួយទៀតហៅថា “អ្នកតាទសមុខ”។ ក្រោយពីបាក់ច្រាំងទន្លេខ្ទមនោះក៏បាត់បង់ទៅ តែគ្រួសារមួយជាអ្នកស្រុកចាស់ ហើយដែលពាក់ព័ន្ធនឹងទំនៀមសម្តែងល្ខោនក៏សាងខ្ទមអ្នកតាទសមុខនោះនៅក្នុងដីផ្ទះរបស់ខ្លួនតែម្តង ព្រោះគេជឿថាបើពុំដូច្នោះទេនឹងកើតហេតុភេទមិនល្អ។[18]

**២.២.២. ទំនៀមទម្លាប់ប្រពៃណី**

**ក. ពិធីច្រត់ព្រះនង្គ័ល**

ពិធីច្រត់ព្រះនង្គ័ល ជាព្រះរាជបវេណីពិធីមួយក្នុងចំណោមព្រះរាជពិធីទ្វាទសមាស (ព្រះរាជពិធីបុណ្យ ដែលធ្វើក្នុងមួយខែម្តងតាមរាជបវេណី)។ តាមធម្មតាព្រះរាជពិធីនេះ ត្រូវបានធ្វើនៅខែពិសាខ(ឧសភា)ជា ពេលដើមរដូវបង្កបង្កើនផលកសិកម្ម ហើយជាទូទៅត្រូវបានប្រារព្ធនៅលើទីលានវាលព្រះមេរុខាងជើងព្រះបរមរាជវាំង ឬព្រះស្រែណាមួយ ដើម្បីប្រកាសរដូវធ្វើស្រែចម្ការ និងទស្សន៍ទាយផលដំណាំសម្រាប់ឆ្នាំបន្ទាប់ផង។

ចំពោះស្នាដៃអក្សរសិល្ប៍រឿងរាមកេរ្តិ៍ ក៏បានបង្ហាញពីពិធីច្រត់ព្រះនង្គ័លនៅក្នុងដំណើរផងដែរ។ នៅក្នុងរឿងរាមកេរ្តិ៍មានតំណាលថា ព្រះនាងសីតាបានចាប់កំណើតក្នុងពេលដែលព្រះបាទជនកកំពុងធ្វើពិធីច្រត់ព្រះនង្គ័ល ហើយក៏លេចចេញព្រះនាងពី

[18] http://www.yosothor.org/publications/khmer-renaissance/chapter-two/rerng-ream-ke-ning-ettiphol-knong-phity.html

ដីអាចម៍បំណះ ដែលព្រះអង្គកំពុងក្ដួចក្នុងព្រះរាជពិធីនោះ។

លុះពិសាខសុកតិត្ថី ផ្ដុំមុខមន្ត្រី នូវយោជន៍នូវប្រែពសុធា។
ដើម្បីនូវធ្វើឱ្យក្សេមដ៏ប្រជា រាស្ត្រវង្សដោយនាក្រិតា ធិការដ៏បុរាណ។
ស្ដេចទ្រង់នង្គ័លហសមាន ព្រះឧសុភរាជបីរូហាន ដំណើរសីហនាទលេលា។
ស្ដេចក្ដួរលុះដ៏ឆ្នេរយមុនា នទីទេពកញ្ញា សុពណ្ណៈពោងពាសកុល ។*(ខ្សែ១ ទំ.៥)*

**ខ. ពិធីអាពាហ៍ពិពាហ៍**

នៅក្នុងប្រពៃណីខ្មែរ ការរៀបចំពិធីអាពាហ៍ពិពាហ៍គឺសំខាន់ខ្លាំងណាស់សម្រាប់កូនប្រុសស្រីក្នុងការរស់នៅជាគូស្វាមីភរិយា។ ជនជាតិខ្មែរយល់ថា ការរស់នៅជាប្ដីប្រពន្ធរបស់មនុស្សប្រុសស្រីទោះបីជាមានការស្រឡាញ់គ្នាយ៉ាងណាក៏ដោយ បើគ្មានពិធីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមប្រពៃណីខ្មែរនោះទេ គឺប្រាកដជាគ្មានសុកមង្គល និងសិរីសួស្តីក្នុងជីវិតគូឡើយ។ នេះបញ្ជាក់ឱ្យឃើញថា ជនជាតិខ្មែរបានប្រកាន់នូវទំនៀមទម្លាប់ប្រពៃណីនៃការផ្សំផ្គុំកូនប្រុសស្រីបានយ៉ាងខ្ជាប់ខ្ជួនបំផុត។

ពិធីរៀបអាពាហ៍ពិពាហ៍ខ្មែរ កើតឡើងដោយមានការរើសពេលាទៅតាមក្បួនតម្រារបស់ខ្មែរ ដែលត្រូវជាថ្ងៃល្អ សិរីសួស្តីសម្រាប់ស្វាមីភរិយាថ្មីថោង។ មួយទៀតទម្លាប់ជនជាតិខ្មែរបុរាណតែងតែ តម្រូវឱ្យកូនប្រុសមកបម្រើបង្ហាញនូវសមត្ថភាពនៅផ្ទះខាងកូនស្រីមួយរយៈ ដើម្បីឱ្យឪពុកម្ដាយកូនស្រីសង្កេតមើលចរិតលក្ខណៈ និងសមត្ថភាពរបស់កូនប្រសារ។ នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍នេះដែរ គឺគេតែងប្រារព្ធឡើងនៅគេហដ្ឋានខាងកូនស្រីដោយមានរៀបចំតាមលំដាប់លំដោយប្រពៃណីដូនតាខ្មែរ។

ទំនៀមទម្លាប់ប្រពៃណីនេះ ក៏បានបង្ហាញនៅក្នុងដំណើររឿងរាមកេរ្តិ៍ ដែលបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យដែរ។ នៅពាក់កណ្ដាលខ្សែទី១ នៃរឿងនេះបានលើកបង្ហាញពីពិធីរៀបអភិសេករបស់ព្រះរាម និងនាងសីតា ដែលបានប្រារព្ធធ្វើឡើងនៅខាងនគរនាងសីតា គឺក្រុងមិថិលា។ ការដែលព្រះរាមទទួលបានព្រះនាងធ្វើជាមហេសីនោះ គឺព្រះរាមបានសាកល្បងឫទ្ធីចេស្ដារបស់ព្រះអង្គក្នុងការលើកធ្នូនៃព្រះបាទជនក ជាបិតាព្រះនាងសីតា និងជាស្ដេចនៃនគរមិថិលា ដែលគ្មានជនណាម្នាក់អាចលើករួចក្រៅពីព្រះរាមឡើយ។ ក្រោយពីព្រះរាមទទួលបានជោគជ័យ ព្រះបាទជនកមានព្រះទ័យត្រេកអរយ៉ាងខ្លាំង ហើយក៏ត្រាស់បញ្ជាឱ្យសេនាមន្ត្រីនាំដំណឹងនេះទៅទូលព្រះបាទទសរថនៃនគរពួយុធ្យា។ ព្រះបាទទសរថពេលជ្រាបនូវដំណឹងដ៏ល្អនេះហើយសប្បាយព្រះទ័យយ៉ាងខ្លាំង ហើយក៏បាននាំមហេសីទាំងបីអង្គបុត្រា និងពួកមន្ត្រីធ្វើដំណើរទៅនគរមិថិលាភ្លាមតែម្ដង។ ពេលទៅដល់ហើយក្សត្រទាំងសងខាងបានរកឫក្សពេលាល្អ ដើម្បីរៀបចំពិធីអភិសេកដល់ព្រះរាម និងព្រះនាងសីតា។

**២.២.៣. អក្សរសិល្ប៍**

រឿងរាមកេរ្តិ៍ជារឿងមួយដ៏ពេលនិយមសម្រាប់បណ្ដាលប្រទេសអាស៊ីអាគ្នេយ៍។ រឿងនេះត្រូវបានប្រែប្រួលរូបរាងសេជាតិពណ៌សម្បុរទៅតាមតំបន់ៗនីមួយៗ។ រឿងរាមកេរ្តិ៍ជារឿងមួយរបស់ទេវៈ ដែលបរិយាយពីការយាងចុះរបស់អវតាព្រះវិស្ណុគឺព្រះរាមដើម្បីមកកម្ចាស់សភាវៈអាក្រក់។ ក្លាយចេញពីអក្សរសិល្ប៍របស់ទេវៈ វាប្រែជារឿងកថាមួយដ៏អស្ចារ្យរបស់ខ្មែរ ដែលបានជាប់ឆ្លាក់ជាប់នឹងជញ្ជាំងនៃប្រាសាទនានា។ មិនត្រឹមតែប៉ុណ្ណោះរឿងរាមកេរ្តិ៍បានក្លាយជាអក្សរសិល្ប៍សំណេរប្រភេទសាស្ត្រារបស់ខ្មែរនាសម័យកណ្ដាល។ ការវិវត្តរបស់រឿងរាមកេរ្តិ៍នៅតែបន្តពីអក្សរសិល្ប៍សំណេរមកជាអក្សរសិល្ប៍សំដី ដែលបាននិទានតៗគ្នា ហើយបានទទួលការចាប់អារម្មណ៍ពីសំណាក់គ្រប់មជ្ឈដ្ឋាន។ មកដល់បច្ចុប្បន្ននេះ យើងឃើញមានបន្សល់ទុកនូវអក្សរសិល្ប៍សំណេរ និងអក្សរសិល្ប៍សំដីដូចជា៖

- រឿងរាមកេរ្តិ៍ ជាប្រភេទសំណេររបស់អ្នកអង្គម្ចាស់វឌ្ឍាធាយាវង្ស (មាន១៦ខ្សែ)
- រឿងរាមកេរ្តិ៍ ជាប្រភេទសំណេរ របស់អ្នកស្រី ពៅ សាវរស (មាន២ភាគ)
- រឿងរាមកេរ្តិ៍ ជាប្រភេទសំណេរ របស់ឧកញ៉ាវាំងវររៀង វាំង ជួន (ឯកសារ តួអង្គរឿងរាមកេរ្តិ៍ របស់រ៉េយំ)
- រឿងរាមកេរ្តិ៍ ជាប្រភេទសំដី (ក្រោយមកកត់ត្រា) របស់ តា មុី ចក់

- រឿងរាមកេរ្តិ៍ ជាប្រភេទសំដី (ក្រោយមកកត់ត្រា) របស់ តា ផ្កាសយ
- រឿងរាមកេរ្តិ៍ ជាប្រភេទសំណេរ របស់ ព្រះវិជ្ជាធរ ព្រះនាមនៅ (ចុះផ្សាយក្នុងទស្សនាវដ្ដីកម្ពុជាសុរិយា ១០៧ភាគ)
- រឿងរាមកេរ្តិ៍ ជាប្រភេទសំណេរ របស់លោក យឹង ហុកឌី(ជាសាស្ត្រា មាន៦៤៣ល្បះ)
- រឿងរាមកេរ្តិ៍ ជាប្រភេទសំណេរ នៅបណ្ណាល័យជាតិ បណ្ណាល័យសារមន្ទីរ បណ្ណាល័យព្រះវិនវត្ថុកេនវង្ស(ជាសាស្ត្រា)
- រឿងរាមកេរ្តិ៍ ជាប្រភេទសំណេរ របស់តាគ្រុឌ (ជាCD)
- រឿងរាមកេរ្តិ៍ក្នុងក្តីស្រមៃ ជាប្រភេទសំណេរ របស់លោកយឹម កិច្ចសែ[19]

ទាំងនេះអាចសបញ្ជាក់ឱ្យយើងឃើញយ៉ាងប្រត្យក្សនូវតម្លៃរឿងរាមកេរ្តិ៍ដែលបានវិវត្តន៍ចេញពីអក្សរសិល្ប៍ទេវៈ មកជាវីរកថា ហើយបន្តមកជាអក្សរសិល្ប៍សំណេរ និងអក្សរសិល្ប៍សំដីឬនិទានរបស់ខ្មែរដែលទទួលការនិយមគាំទ្រយ៉ាងខ្លាំងក្នុងសង្គមខ្មែរ។

**២.២.៤. សិល្បៈ របាំ**

នៅក្នុងទម្រង់នៃសិល្បៈខ្មែរ រឿងរាមកេរ្តិ៍បានចាក់គ្រឹះយ៉ាងមាំចូលទៅស្ទើរគ្រប់ទម្រង់។ទាំងនេះជាពិពិធភាពមួយដ៏អស្ចារ្យនៃឥទ្ធិពលរឿងរាមកេរ្តិ៍ក្នុងសង្គមវប្បធម៌ដែលបានបានស្តែងឱ្យឃើញ នូវសិល្បៈរស់រវើកនៃជនជាតិខ្មែរ។

**ក. ចម្លាក់**

រឿងរាមកេរ្តិ៍ជារឿងដ៏ល្បីល្បាញនិងមានឥទ្ធិពលនៅក្នុងសង្គមខ្មែរពីបុរាណកាលរហូតមកដល់បច្ចុប្បន្ននេះ។ ដើម្បីបន្សល់ទុកនូវកិត្តិនាមដ៏ល្បីល្បាញនៃរឿងនេះ បុព្វបុរសខ្មែរបានដាប់ឆ្លាក់នូវដំណើររឿងរាមកេរ្តិ៍នៅតាមប្រាសាទបុរាណនានាដូចជា ប្រាសាទកោះកេរ(ដើមស.វ.ទី១០) ប្រាសាទបន្ទាយស្រី(ដើមស.វ.ទី១០) ប្រាសាទបាពួន (ដើមស.វ.ទី១១) ប្រាសាទអង្គរវត្ត (ដើមស.វ.ទី១២) ជាដើម[20]។

និយាយតែតាមចម្លាក់ឃើញនឹងភ្នែក គឺមានតាំងតែពីស.វ.ទី៧មកម៉្លេះ ដូចមានឧទាហរណ៍ពីប្រាសាទភ្នំដាក្នុងខេត្តតាកែវជាដើម។ នៅសតវត្សទី៩យើងឃើញមានចម្លាក់រឿងរាមកេរ្តិ៍មួយជុំនៅលើខឿនជាន់ទី៥នៃប្រាសាទបាគង។ នៅអង្គរវត្តនាស.វ.ទី១២ មានចម្លាក់រឿងរាមកេរ្តិ៍នៅរោងទងខាងលិចចំហៀងខាងជើងប្រវែង៥០ម៉ែត្រ ព្រមទាំងនៅតាមផ្នែកនានាជាច្រើននៃប្រាសាទនេះផង។ ប្រាសាទនៅសម័យអង្គរមានសន្ទឹកសន្ទាប់ទៀតគេក៏មានឆ្លាក់ឈុតនេះឈុតនោះនៃរឿងរាមកេរ្តិ៍នៅតាមចំណុចផ្សេងៗរាប់មិនអស់ ដូចជានៅប្រាសាទធំៗមួយចំនួន៖ បន្ទាយស្រី, បាភួន, បន្ទាយសម្រេ, បន្ទាយក្តី, ព្រះខ័ន។ល។ ចំពោះនៅសម័យថ្មីរវាង ស.វ.ទី១៩-២០ឯណេះវិញក៏សម្បូណ៌ណាស់ដែរ ហើយដែលនៅមានសេសសល់គំនូរឬចម្លាក់រឿងរាមកេរ្តិ៍តាមព្រះវិហារជាច្រើន ទោះបីយើងប្តូរមកប្រតិបត្តិតាមព្រះពុទ្ធសាសនាថេរវាទច្បាស់លាស់តាំងពីរវាងស.វ.ទី១៤មក យ៉ាងណាក្តី។ ក្នុងនោះមានដូចជានៅថែវជុំវិញព្រះវិហារព្រះកែវមរកតនៃព្រះបរមរាជវាំង ព្រះវិហារវត្តដំរីស ខេត្តបាត់ដំបង ព្រះវិហារវត្តរាជបូព៌ ខេត្តសៀមរាប និងនៅទីដទៃៗសន្ទឹកសន្ទាប់រាប់មិនអស់ឡើយ[21]។

នៅក្នុងចម្លាក់រឿងរាមកេរ្តិ៍ តួអង្គមួយចំនួនក៏បានឆ្លាក់ចម្លាក់លោត ធ្វើជារូបសំណាកនៅតាមសួនច្បារ កន្លែងផ្សេងៗ នៅរាជធានីខេត្តមួយចំនួនមកដល់បច្ចុប្បន្ន។ ឧទាហរណ៍ដូចជា រូបពាលីកាត់កទូភី ព្រះរាមផ្លែងសរ នៅខេត្តកំពង់ចាម រូបសុវណ្ណមច្ឆា និងហនុមាន រូបព្រះនារាយណ៍ នៅខេត្តបាត់ដំបង រូបពាលីនិងទូភី រូបមច្ឆានុត នៅបន្ទាយមានជ័យ រូបព្រះរាមផ្លែងសរគង់លើសុគ្រីព នៅខេត្តសៀមរាបជាដើម។

---

[19] *ទាំងនេះជារឿងរាមកេរ្តិ៍ដែល បណ្ឌិត ជា វណ្ណី បានយកមកសរសេរក្នុងនិក្ខេបបទរបស់គាត់ (សូមមើលជា វណ្ណី, រាមកេរ្តិ៍ក្នុងសង្គមខ្មែរ, និក្ខេបបទ,រាជបណ្ឌិត្យសភា, ២០១៣,)*

[20] *សរ សារុន, សង្ខេបរឿងរាមកេរ្តិ៍, ដ-ឯ-ម., ទំ.២*

[21] *អាំងដួលាន ព្រាបចាន់ម៉ារ៉ា ស៊ីយ៉ុនសុភារិទ្ធ គងវីរៈ, កម្រងអត្ថបទក្នុងបណ្តាញពតិមានវប្បធម៌ខ្មែរ លេខ១៣, យសោធរ, ២០១៨, ទំ.៦៣-៦៥*

## ខ. គំនូរ

សិល្បៈគំនូរក្នុងរឿងរាមកេរ្តិ៍ ភាគច្រើនត្រូវបានផ្ញើខ្លួនជាមួយនឹងវត្តអារាម។ ក៏ទោះបីជាវត្តអារាមជាទីកន្លែងនៃពុទ្ធសាសនាក៏ដោយ តែការគូរគំនូររឿងរាមកេរ្តិ៍នេះ ហាក់បង្ហាញនូវសុខុដុមនីយមកម្មនៃសាសនានៅក្នុងកម្ពុជា មិនថាពុទ្ធសាសនាឬព្រាហ្មណ៍សាសនា។ គេអាចឃើញសិល្បៈគំនូររឿងរាមកេរ្តិ៍ពេលលេញនេះ យ៉ាងប្រត្យក្សនៅលើថែវនៃព្រះវិហារព្រះកែវមរកត ដែលបានគូរឡើងនាឆ្នាំ១៨៩២ ដល់ឆ្នាំ១៩០៣ ដោយលោកឧកញ៉ា ទេព និម្មិតម៉ក់ ជាស្ថាបត្យករផង និងជាវិស្វករផង។មួយវិញទៀត យើងក៏អាចឃើញគំនូរមួយចប់នេះ នៅវត្តរាជបូណ៌។ តាមរយៈលោកតាសំ សួស ជាចាស់ទុំក្នុងវត្ត ដែលជាអតីតបុព្វជិតក្នុងវត្តនេះដែរ បានឱ្យដឹងថា គំនូររឿងរាមកេរ្តិ៍ក្នុងវត្តរាជបូណ៌នេះប្រហែលជាគូរនៅឆ្នាំ១៨២០ [22] ។ ជាការពិតណាស់ រឿងរាមកេរ្តិ៍នេះមិនមែនមានតែទីតាំង២កន្លែងនេះទេ យើងឃើញមាននៅតាមវត្តអារាមមួយចំនួនទៀតដូចជា ព្រះវិហារប្រាសាទភ្នំជីសូរ្យ នៅខេត្តតាកែវ(ខ្ទេចខ្ទីនៅដើមទសវត្សរ៍ទី៧០) វិហារវត្តព្រែកប្រាំងខេត្តកណ្តាលជាដើម។ ក្រៅពីនេះគេដកស្រង់វគ្គខ្លីៗមកគូរនៅតាមវត្តមួយចំនួនដូចជា៖ នៅវត្តកំពង់ត្រឡាចលើ ក្នុងខេត្តកំពង់ឆ្នាំង វត្តបាក់ជាវ និងវត្តមហាអម្ពនៃក្នុងខេត្តកណ្តាល វត្តកំពង់អំពិលក្នុងខេត្តព្រៃវែង វត្តកងតាណឹង និងវត្តពោធិគ្រងក្នុងខេត្តកំពង់ចាម វត្តខ្សាច់ពោច និងវត្តសូភីក្នុងខេត្តបាត់ដំបង និងវត្តអង្គរខាងជើង និងវត្តពោធិ៍រុក្ខារាមក្នុងខេត្តសៀមរាបជាដើម[23]។

## គ. ទស្សនីយភាព

### គ.១. របាំក្បាច់បុរាណ

រឿងរាមកេរ្តិ៍ ជារឿងមួយដែលគេយកដំណើររឿងទៅបង្កើតបានជាក្បាច់ ឈុត ឆាកនៃរបាំយ៉ាងមានប្រជាប្រិយភាព។ យើងឃើញថា រឿងរាមកេរ្តិ៍នៅក្នុងវិស័យរបាំ គឺមានភាពលេចធ្លោយ៉ាងខ្លាំង ដែលគេតែងតែស្គាល់របាំនៃរឿងរាមកេរ្តិ៍នេះថា របាំព្រះរាជទ្រព្យ ឬរបាំក្បាច់បុរាណ។ ឈុតមួយចំនួនបានក្លាយជារបាំដូចជា របាំសុវណ្ណមច្ឆា(គឺនៅពេលដែលហនុមានទៅជួបនឹងសុវណ្ណមច្ឆា) របាំស្វា ជាដើម។ “*របាំព្រះរាជទ្រព្យ*” ត្រូវបានចុះក្នុងបញ្ជីជាសម្បត្តិបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ កាលពីថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ។

### គ.២. ល្ខោនព្រះរាជទ្រព្យ

ក្នុងទម្រង់ល្ខោនព្រះរាជទ្រព្យ ឬល្ខោនក្បាច់បុរាណ រឿងរាមកេរ្តិ៍បាននៅជិតដាមជាប់យ៉ាងខ្លាំង។ នៅក្នុងល្ខោនព្រះរាជទ្រព្យគេឃើញមាន តួអង្គបួនសំខាន់ៗគឺ តួនាយរោង(តួប្រុស) តួនាង(តួស្រី) តួយក្ស និងតួស្វា។ ល្ខោនព្រះរាជទ្រព្យរឿងរាមកេរ្តិ៍នេះមានប្រជាប្រិយភាពខ្លាំងណាស់។ ជារៀងរាល់ឆ្នាំគេតែងប្រារព្ធពិធីបុណ្យរឿងរាមាយណៈ (Ramayana Festival) ក្នុងបណ្តាប្រទេសដែលមានរឿងនេះ។ កាលពីឆ្នាំ២០១៩ ប្រទេសឥណ្ឌូណេស៊ីបានធ្វើជាម្ចាស់ផ្ទះក្នុងការប្រារព្ធពិធីបុណ្យរាមាយណៈ លើកទី៥ រយៈពេលបីថ្ងៃ។ ជាមួយគ្នានេះដែរ នៅដើមឆ្នាំ ១៩៩៦ នៅអង្គរវត្តខេត្តសៀមរាបមានបើកមហោស្រព អន្តរជាតិអង្គរដែលមានប្រទេស៧ ចូលរួមគឺ ឥណ្ឌា សិង្ហបុរី ឡាវ ថៃ ឥណ្ឌូណេស៊ី ម៉ាលេស៊ី និងកម្ពុជា ក៏សម្តែងរឿងរាមកេរ្តិ៍នេះដែរ[24]។ ល្ខោនព្រះរាជទ្រព្យនេះត្រូវបានទំនុបបម្រុងយ៉ាងខ្លាំងពីសំណាក់ **សម្តេចព្រះរាជបុត្រី ព្រះរៀម នរោត្តម បុប្ផាទេវី** ទេពនារីដ៏ឯកដែលសម្តេចជាតួអង្គសំខាន់ និងជានិមិត្តរូបមួយនៃល្ខោនព្រះរាជទ្រព្យខ្មែរ។

---

[22] *ជា វណ្ណី, រាមកេរ្តិ៍ក្នុងសង្គមខ្មែរ, ដ-ឯ-ម., ទំ. ២៣៧*

[23] *វៃ យ៉ំ(សាន ផល្លា) គំនូរនៅតាមវត្ត, ទំ.១៥៣*

[24] *កក់ ច័ន្ទថាត, គំនូរបុរាណរឿងរាមកេរ្តិ៍ ដ-ឯ-ម., ទំ.១៦២*

**គ.៣. ល្ខោនខោល**

នាពេលថ្មីៗនេះ កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ល្ខោនខោលវត្តស្វាយអណ្ដែតត្រូវបានចូលជាបេតិកភណ្ឌអរូបីនៃមនុស្សជាតិ របស់អង្គការយូណេស្កូ។ កាលចូលនេះរឹតតែបានធ្វើឱ្យសាកលលោកបានស្គាល់នូវទ្រង់ល្ខោនខោលមួយនេះ។

ល្ខោនខោលជាល្ខោនសក្ការៈមួយដែលដែលសម្ដែងតែនៅក្នុងរឿងរាមកេរ្តិ៍ប៉ុណ្ណោះ។ ហើយលក្ខណៈពិសេសនៃល្ខោននេះគឺសុទ្ធតែបុរសជាអ្នកសម្ដែង។ បើតាមលោកឧកញ៉ា ទេពពិទូរ ក្រសេម គន្ថបណ្ឌិត បាននិយាយថា " ចំណែកល្ខោនខោល គេកំណត់លេងចំពោះតែរឿងដែលទាក់ទាមដោយរឿង ព្រះជាម្ចាស់ ព្រះឥសូរ ព្រះនារាយណ៍ដែលជា ព្រះក្នុងសេយ្យសាស្ត្រ គឺលេងរឿងអវតារ (បែងភាគ) របស់ព្រះជាម្ចាស់ ដូចយ៉ាងរឿងរាមកេរ្តិ៍ (រាមាយណៈ ) សឹងតែជាប្រវត្តិព្រះជាម្ចាស់នោះ " ។

**គ.៤. ល្ខោនស្បែកធំ**

ល្ខោនស្បែកធំក៏ជាល្ខោនសក្ការៈមួយរបស់ខ្មែរ ដែលមានតាំងយូរលង់ណាស់មកហើយ។ ល្ខោនស្បែកធំត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបី នៃមនុស្សជាតិ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់អង្គការយូណេស្កូ។ ល្ខោនស្បែកធំនេះ ត្រូវបានសម្ដែងតែក្នុងរឿងរាមកេរ្តិ៍ប៉ុណ្ណោះ។ ល្ខោនស្បែកធំ គឺជាសិល្បៈមួយមានប្រវត្តិនៅពេលព្រាហ្មសាសនាចូលមកទឹកដីខ្មែរ។ កាលពីដើមឡើយ សិល្បៈប្រភេទនេះត្រូវបានគេឃើញសម្ដែងក្នុងពិធីតែពីរ ឬបីប៉ុណ្ណោះក្នុងមួយឆ្នាំ ហើយកម្រសម្ដែងជាសាធារណៈណាស់។ ពិធីទាំងនោះមានដូចជាពិធីបុណ្យចូលឆ្នាំខ្មែរ ពិធីបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ និងពិធីគ្រងរាជ្យឬក្នុងពិធីសក្ការៈរបស់ឥស្សរជនល្បីៗ។ តរៀងមកក្នុងវេលាសម្ដែងគេឃើញសម្ដែងក្នុងពិធីមួយចំនួនដូចជា ព្រះសពព្រះមហាក្សត្រ គ្រូបាធ្យាយ ឬសពមាតាបិតា ឬពេលខ្លះសម្ដែងដើម្បីសុំទឹកភ្លៀង ក្នុងពេលដែលស្រុកទេសជួបប្រទះគ្រោះរាំងស្ងួត[25] ។ ការសម្ដែងរឿងរាមកេរ្តិ៍ទៀតសោត គេមិនសម្ដែងពីដើមដល់ចប់នោះទេគ្រាន់តែតែសម្ដែងជាឈុតផ្សេងៗដូចជា ចម្បាំងឥន្ទ្រជិតជាមួយព្រះលក្ស្មណ៍ជាដើម។

មិនត្រឹមតែប៉ុណ្ណោះ យោងតាមលិខិតជូនដំណឹងរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានឱ្យដឹងថា នៅក្នុងថ្ងៃគំរប់ខួប ១៥ឆ្នាំនៃការដាក់បញ្ចូលល្ខោនស្រមោលស្បែកធំជាសម្បត្តិបេតិកភណ្ឌពិភពលោក **សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គសព្វព្រះរាជហឫទ័យប្រោសព្រះរាជទានព្រះរាជបូជាត្ថម្ភដ៏ឧត្តុង្គឧត្ដមវិសេសវិសាលបំផុត ចំពោះការចម្លងឡើងវិញនូវស្បែកធំមួយឈុតចំនួន ៩០ ផ្ទាំង សម្រាប់តម្កល់បម្រើជាឧត្តមប្រយោជន៍របស់ជាតិកម្ពុជា ។

ទាំងនេះសបញ្ជាក់ឱ្យឃើញពីការឱ្យតម្លៃ និងនិយមរឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរតាំងពីព្រះមហាក្សត្រ ហូតដល់ប្រជានុរាស្ត្រ។

**គ.៥ ទម្រង់សិល្បៈដទៃ**

ជាការពិតណាស់ក្រៅអំពីល្ខោនសក្ការៈធំៗខាងលើរឿងរាមកេរ្តិ៍ក៏មាននោះវត្តមាននៅក្នុងសិល្បៈដទៃទៀតផងដែរ។ តួយ៉ាងនៅក្នុងល្ខោនពោលស្រី របស់ស្រុកកៀនស្វាយក្រៅ ក៏បានសម្ដែងរឿងរាមកេរ្តិ៍ផងដែរ។ ល្ខោនពោលស្រី ជាទម្រង់ល្ខោនបុរាណនិងល្ខោនខោល ប៉ុន្តែតួអង្គសម្ដែងមាននិយាយពាក្យសម្ដី និងច្រៀងប្រកបជាមួយភ្លេងពិណពាទ្យ មានពាក្យពោល មានចម្រៀងជាក្រុម ច្រៀងជូន កាយវិការ(ក្បាច់) តួទាំងអស់ត្រូវឱ្យដៃ ទៅតាមពាក្យពោលនិងចម្រៀង[26]។ ល្ខោននេះដូចជាកូនពៅនៃល្ខោនព្រះរាជទ្រព្យ ដែលសុទ្ធតែស្រីជាអ្នកសម្ដែង។

មិនត្រឹមតែល្ខោនពោលស្រី យើងឃើញមានល្ខោនយីកេ ក៏យករឿងរាមកេរ្តិ៍មកសម្ដែងដែរ។ ថ្ងៃសៅរ៍ ទី២៥ ខែសីហា ឆ្នាំ ២០១៨ ល្ខោនយីកេរបស់ក្រុមយីកេអមតៈបានសម្ដែងឈុតមួយក្នុងរឿងរាមកេរ្តិ៍ “សីតាគូររូបក្រុងរាពណ៍” នៅឆាកសិល្បៈខ្មែរ អមតៈ សារមន្ទីរជាតិកម្ពុជា។

---

[25] *គណៈកម្មការស្រាវជ្រាវវប្បធម៌ខ្មែរ,ទស្សនីយភាពខ្មែរ, រដ្ឋសភាកម្ពុជា, ២០០៣, ទំ៧២*

[26] *ចិន្ត នាគ, ល្ខោនពោលស្រី, អម្រឹតាសិល្បៈ, ២០០៣, ទំ.១៦*

រីឯក្នុងសិល្បៈចាប៉ីដងវែងវិញ អ្នកកិរម្យរវោហា ប្រាជ្ញ ឈួន ក៏បានយករឿងរាមកេរ្តិ៍នេះទៅច្រៀងរៀបរាប់ផងដែរដែលមានរយៈពេល១ ម៉ោង។

ក្នុងទម្រង់នៃកូនពៅនៃសិល្បៈខ្មែរទាំង៧ គឺភាពយន្ត។ ជាក់ស្តែង ភាពយន្តរឿងរាមកេរ្តិ៍ត្រូវបាន ដឹកនាំដោយលោក ហង្ស សុវណ្ណារ៉ា របស់ផលិតកម្មរតេកភាពយន្ត ដែលមានរយៈពេល២ម៉ោងជាង។នៅក្នុងរឿងនេះ អ្នកដឹកនាំរឿងលើកយកតែផ្ទៃរឿងចាប់ពីខ្សែទី៧៥-៨០ មកសម្តែងតែប៉ុណ្ណោះ។

ទន្ទឹមនឹងនេះ ក្នុងភាពយន្តនោះក៏មានចម្រៀងរាមកេរ្តិ៍ ដែលច្រៀងដោយ អ្នកស្រី ហ៊ឹម ស៊ីវន។ បទបុណ្យភូមិ របស់ក្រុមក្មេងខ្មែរ(បង្ហាញពេលយាយថៃនាងសីតា)។ បទកំហុសរាម ច្រៀងដោយ T-M ផលិតកម្ម RAY MOND។ បទយក្សយំ ច្រៀងដោយ MR-K – JULAY ផលិតកម្ម RAY MOND។

### ២.២.៥. ផ្សេងៗ

#### ក. រូបសញ្ញា(Logo)

នៅក្នុងស្ថាប័នរដ្ឋមួយចំនួន គេឃើញមានយករូបតួអង្គនៅក្នុងរឿងរាមកេរ្តិ៍ មកប្រើប្រាស់ជានិម្មិតសញ្ញាតំណាងកន្លែងស្ថាប័នទាំងនោះ។ តួយ៉ាងដូចជានៅក្រសួងការពារជាតិ កងយុទ្ធពលខេមរភូមិន្ទខ្មែរ ដែលស្ថាប័នទាំងនេះបានយករូបតួអង្គហនុមានកាន់ព្រះខ័នធ្វើជានិមិត្តរូបនៃកងទ័ពជាតិ។ ការដាក់រូបហនុមាន គឺជាការតំណាងឱ្យអ្នកក្លាហានក្នុងការការពារបូរណភាពទឹកដីជាសេនារបស់ព្រះរាម តំណាងវីរភាព និងភក្តីភាពរបស់មេទ័ព ចំពោះព្រះមហាក្សត្រ គឺព្រះរាមក្នុងការផ្ចាញ់មារ។ ម៉្យាងទៀតហនុមានក៏ជាតំណាងក្នុងការការពារឧបទ្រពចង្រៃផងដែរ ព្រោះយើងឃើញមានចម្លាក់រូបហនុមាននៅលើសន្លឹកមាសស្តើង ដែលបុព្វបុរសខ្មែរប្រើជាយន្ត អាថាន់ ដើម្បីការពារទប់ទល់នឹងឧបទ្រពចង្រៃ[27]។

រីឯនៅក្នុងសហព័ន្ធកីឡាហែលទឹកកម្ពុជាក៏បានយករូបនាងសុវណ្ណមច្ឆាជានិមិត្តរូបរបស់សហព័ន្ធរបស់ខ្លួនដែរ។ ការដាក់នេះតំណាងឱ្យតួអង្គនៅរឿងរាមកេរ្តិ៍ គឺនាងសុវណ្ណមច្ឆា ដែលជាមេដឹកនាំនៅក្នុងទឹកដ៏សំខាន់មួយរូប។

កត្តានេះហើយ ជាសក្ខីភាពបង្ហាញនូវភាពល្បីល្បាញនៃរឿងរាមកេរ្តិ៍ខ្មែរ ដែលអ្នកសិក្សាពីវិស័យអក្សរសាស្ត្រ អក្សរសិល្ប៍ខ្មែរ មានការសរសើរយ៉ាងខ្លាំងពីតម្លៃនៃរឿងរាមកេរ្តិ៍ខ្មែរ។

#### ខ. ការដាក់ឈ្មោះ

រឿងរាមកេរ្តិ៍ មានឥទ្ធិពលទៅដល់ការដាក់ឈ្មោះទៅលើរបស់ផ្សេងៗ នៅក្នុងការរស់នៅរបស់ប្រជាជនខ្មែរ។ នៅក្នុងនោះគេប្រទះឃើញដូចជាការយកឈ្មោះតួអង្គនៅក្នុងរឿងរាមកេរ្តិ៍មកដាក់ឈ្មោះឱ្យទូកង ដែលជាទូកសម្រាប់ប្រណាំង ដោយគេមានជំនឿទៅលើឈ្មោះទាំងនោះថានឹងនាំភាពជ័យជម្នះដល់ទូករបស់ពួកគេ។

ក្នុងជំនឿទៅលើទូកង គេឃើញមាន រូបកំហែងហនុមាននេះតែងឃើញមានជាប់នឹងទូកប្រណាំងនៅតាមវត្តផ្សេងៗក្នុងតំបន់ដែលលើកមកនេះ ថែមទាំងមានឈ្មោះនៅជាប់លើនោះផង។ ឧទាហរណ៍មានឈ្មោះថា «កំហែង បរមី» ឬ «កំហែងកុមារមហាហង្សសែនជ័យ» ជាដើម។[28] ក្រៅពីនេះមានឈ្មោះទូកមួយចំនួនទៀតដែលដកស្រង់ចេញពីរឿងរាមកេរ្តិ៍ដូចជា កំហែងរាមាសរព្រះរាមមានរិទ្ធិ ជម្ពូពានមានឫទ្ធិ ជម្ពូពានមានជ័យជាដើម។

ដូចគ្នាដែរ រុក្ខជាតិមួយចំនួនក៏ត្រូវបានគេយកតួអង្គនៅក្នុងរឿងរាមកេរ្តិ៍មកដាក់ជាឈ្មោះនៃរុក្ខជាតិទាំងនោះដែរ មានដូចជា៖ ដើមលំពែងព្រះរាម ដើមសុកព្រះរាម ដើមពុកព្រះរាម ដើមសេដា ដើមសម៉ពិភេក។ល។ ចំពោះការដាក់ឈ្មោះរុក្ខជាតិ ដែលយកតួអង្គក្នុងរឿងរាមកេរ្តិ៍មកដាក់តំណាងឈ្មោះរុក្ខជាតិទាំងនោះ សបញ្ជាក់ឱ្យឃើញថា រឿងរាមកេរ្តិ៍បានរស់នៅជាមួយប្រជាជន

---

[27] *ជា វណ្ណី, រាមកេរ្តិ៍ក្នុងសង្គមខ្មែរ*, ដ-ឯ-ម., ទំ.៣១៤

[28] http://www.yosothor.org/publications/khmer-renaissance/chapter-two/rerng-ream-ke-ning-ettiphol-knong-phity.html

ខ្មែរតាំងពីយូរយាណាស់មក ហើយវាបានជះឥទ្ធិពលយ៉ាងខ្លាំង ដល់ការរស់នៅរបស់មនុស្សតាំងពីសម័យបុរាណមកទល់នឹងបច្ចុប្បន្ននេះទៀត។

**គ. ក្បាច់គុណប្រដាល់**

កីឡាជាផ្នែកមួយដ៏សំខាន់ក្នុងការជួយទ្រទ្រង់សុខភាពមនុស្សឱ្យរឹងមាំ។ ក្នុងនោះនាពេលខាងមុខក្រសួងវប្បធម៌បាននឹងកំពុងរៀបចំក្បាច់គុណល្បុក្កតោចូលជាសម្បត្តិបេតិកភណ្ឌអរូបីមនុស្សជាតិទៀតផង។ យើងងាកមកមើលនៅក្នុងក្បាច់ប្រដាល់សេរីគុនខ្មែរគេឃើញមានការគុនគ្រូមួយចំនួនយកលំនាំតាមតួអង្គនៅក្នុងរឿងរាមកេរ្តិ៍ដូចជា ការគុនគ្រូតាមបែបព្រះរាមផ្លែងសរ ការគុនគ្រូតាមរបៀបព្រះរាមព័ទ្ធសីមា ការគុនគ្រូតាមរបៀនហនុមានលេងទឹក ជាដើម។ ទាំងនេះសឱ្យឃើញពីឥទ្ធិពលជំនឿនៃរឿងរាមកេរ្តិ៍នៅក្នុងសង្គមខ្មែរ រួមមានទាំងក្នុងវិស័យប្រដាល់នេះផងដែរ។

**ឃ. វិស័យសុខាភិបាល**

រឿងរាមកេរ្តិ៍ក៏បានបង្ហាញពីប្រព័ន្ធសុខាភិបាលបែបបុរាណផងដែរ។ ជាការពិតណាស់ ទោះបីជាវេជ្ជសាស្ត្របច្ចុប្បន្នរីកចម្រើនយ៉ាងណា តែការព្យាបាលតាមបែបបុរាណដោយប្រើឱសថបុរាណនៅតែពេញនិយមក្នុងសង្គមខ្មែរ។ តួយ៉ាងនៅពេលព្រះលក្ស្មណ៍ត្រូវមោង្គស័ក្តិរបស់កុម្ភការណ៍ ពិភេកបានព្យាបាលរបួសនេះតាមបែបវេជ្ជសាស្ត្របុរាណ ដោយចាត់ឱ្យហនុមានទៅរកដើមឈើនៅព្រៃហិមពាន្ត និងថ្មនៅក្រោមក្បាលដំណេករបស់រាពណ៍។

| | | |
|---|---|---|
| ពិភេកមើលយល់នូវតម្រា | ប្រើហនុមានជា | ជំនិតជំនឿចក្រី។ |
| ឱ្យយកព្រះសង្គណី | មួយយកឫស្សរី | កេសរបុទុមសោភា។ |
| មួយយកនពតដាកមហា | ស្រះស្រង់វងថ្លា | នូវមូត្រឧសភរាជថ្វាត់។ |
| ហនុមានមហិមានិរព័ទ្ធ | លាព្រះវរក្សត្រ | ក៏ហោះឆ្ពោះព្រៃហេមពាន្ត។ ***(ខ្សែ១ ទំ. ១៧)*** |

## សន្និដ្ឋាន

ជារួមយើងឃើញថា រឿងរាមកេរ្តិ៍ជាវណ្ណកម្មមួយដ៏សំខាន់ក៏ទោះជារឿងនេះត្រូវបាននាំយកមកពីឥណ្ឌាក៏ពិតមែន តែកវីនិពន្ធខ្មែរបានកែខៃឱ្យទៅជារសជាតិខ្មែរ ប្រកបដោយសិល្បិ៍វិធីខ្ពស់។ រឿងរាមកេរ្តិ៍ពិតជាមានតម្លៃក្នុងអរិយធម៌ខ្មែរ ទាំងផ្នែកសង្គមធម៌និងផ្នែកវប្បធម៌។ វាជាទស្សនាទានមួយដ៏ល្អសម្រាប់មេដឹកនាំក្នុងការគ្រប់គ្រងប្រទេស ឱ្យមានសន្តិភាពនិងវឌ្ឍភាពដោយជៀសវាងពីបញ្ហាសង្គ្រាមផ្សេងៗ ដែលត្រង់នេះបង្ហាញឱ្យមេដឹកនាំចេះគិតប្រយោជន៍រួមជាធំ មិនត្រូវអស្មិមានះ ប្រកាន់យកមតិខ្លួនជាធំ នាំឱ្យអន្តរាយដល់នគរទៀតផង។ មួយវិញទៀតរឿងរាមកេរ្តិ៍ត្រូវបានចាក់ឫសយ៉ាងមាំក្នុងវប្បធម៌ខ្មែរ ពីអក្សរសិល្ប៍របស់ទេវ មកជាអក្សរសិល្ប៍បែបមនុស្សវិទ្យា មានលក្ខណៈចម្រុះទៅលើលោកិយសច្ចៈ។ មិនត្រឹមតែប៉ុណ្ណោះ រឿងនេះបានសាបព្រោះនូវទម្រង់សិល្បៈខ្មែរឱ្យមានរីកស្រស់ស្រាយ និងចម្រុះពណ៌ ដូចជាក្នុងល្ខោនព្រះរាជទ្រព្យ របាំព្រះរាជទ្រព្យ ល្ខោនខោល ល្ខោនពោលស្រី ល្ខោនយីកេ ភាពយន្ត ចម្រៀងជាដើមនោះ។ ក្លាយចេញពីសិល្បៈ ទំនៀមទម្លាប់ មកជាជំនឿ តួអង្គមួយចំនួនបានក្លាយជាអ្នកតា ដែលបានផ្តល់ក្តីសុខទៅកាន់ប្រជាជនទៀតផង។

សរុបមកពិពិធភាពទាំងនេះហើយដែលធ្វើឱ្យតម្លៃអក្សរសិល្ប៍រឿងរាមកេរ្តិ៍ស្ថិតនៅជានិរន្តក្នុងសង្គមខ្មែរ។ ដូចនេះការសិក្សារឿងរាមកេរ្តិ៍ជាកម្មវត្ថុមួយដ៏សំខាន់សម្រាប់សិស្ស និស្សិត ក៏ដូចជាជនានុជនទាំងអស់ ដើម្បីឈ្វេងយល់ពីតម្លៃនិងទស្សនៈរបស់រឿង យកមកពិនិត្យ ពិចារណា រកឱ្យឃើញមាគ៌ាមួយឆ្ពោះទៅរកសុខដុមភាពនៃសង្គម និងមានការរីកចម្រើនតរៀងទៅ៕

# គន្ថនិទ្ទេស


## ក. ជាឯកសារ

- កក់ ច័ន្ទថាត, គំនូរបុរាណរឿងរាមកេរ្តិ៍ , ភ្នំពេញ, ១៩៩៦
- គណៈកម្មការស្រាវជ្រាវវប្បធម៌ខ្មែរ,ទស្សនីយភាពខ្មែរ, រដ្ឋសភាកម្ពុជា, ២០០៣
- ចិន្ត នាគ, ល្ខោនពោលស្រី, អម្រឹតាសិល្បៈ, ២០០៣
- ឃឹង ហុកឌី, ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ, បណ្ណាគារអង្គរ, ២០០៣
- ឃឹង ហុកឌី, សាស្ត្រារាមកេរ្តិ៍ កាលវែរពណ៌សណ្ដំយកព្រះរាមបាន,បណ្ណាគារអង្គរ, ២០០៤
- ជួន ណាត, វចនានុក្រមខ្មែរភាគ១ ភាគ២, ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៨
- ជា វណ្ណី, រាមកេរ្តិ៍ក្នុងសង្គមខ្មែរ, និក្ខេបបទ,រាជបណ្ឌិត្យសភា, ២០១៣
- ឈិន យួន, ជំនឿផ្សេងៗនៃជនជាតិខ្មែរ,បណ្ណាគារ អប្សរា,១៩៩៩
- ទីតូ, ការបញ្ជាក់ពីប្រភពរឿងរាមកេរ្តិ៍ នៅក្នុងកាសែតរស្មីកម្ពុជា ឆ្នាំទី៨ លេខ២២២៥ ថ្ងៃព្រហស្បតិ៍ទី១៧ ខែសីហា ឆ្នាំ ២០០០
- ធន់ ហ៊ិន, រឿងរាមាយណៈ, ២០០៤
- ប៉ាន់ វុត្ថា, គ្រឹះទស្សនវិជ្ជាខ្មែរ, និក្ខេបបទ,រាជបណ្ឌិត្យសភា, ២០១៣
- ពុទ្ធសាសនបណ្ឌិត្យ, រាមកេរ្តិ៍ ១៦ខ្សែ, ភ្នំពេញ, ២៥៣៩
- ព្រាប ចាន់ម៉ារ៉ា, រឿងរាមកេរ្តិ៍ ក្នុងជំនឿ ទំនៀមទម្លាប់ សិល្បៈនិងសង្គមខ្មែរ(ស្លាយបាវកថា)
- វ៉ៃ យំ(សាន ផល្លា) គំនូរនៅតាមវត្ត
- រាមកេរ្តិ៍ពោលដោយតាសយ, ចម្លងដោយពិន ប៊ុន្នីន, ពុទ្ធសាសនបណ្ឌិត្យ, ២០០០
- រឿងរាមកេរ្តិ៍នៃតាចក់, ពុទ្ធសាសនបណ្ឌិត្យ, ២០០២
- លាង ហាប់អាន,សិក្សាអត្ថបទរឿងរាមកេរ្តិ៍, ១៩៩៩(វាយឡើងវិញ)
- ស៊ុំ ឈុំប៊ុន, អក្សរសិល្ប៍ឥណ្ឌា, ភូមិន្ទភ្នំពេញ, ១៩៩៥,
- សែម សូរ, បរមាធិប្បាយពិសេស, បណ្ណាគារភ្នំពេញ, ១៩៧០
- សរ សារុន, រាមកេរ្តិ៍, ១៩៧៥
- សិក្សាអត្ថបទ ទុំទាវ រាមកេរ្តិ៍,១៩៨៨
- សាគូ សាម៉ុត, ប្រវត្តិសាស្ត្រកម្ពុជានិងវរជនខ្មែរ, បណ្ណាគារអង្គរ, ២០០៣
- អាំងជូលាន ព្រាបចាន់ម៉ារ៉ា ស៊ីយ៉ុនសុភារិទ្ធ គង់វីរៈ, កម្រងអត្ថបទក្នុងបណ្ដាញពត៌មានវប្បធម៌ខ្មែរ លេខ១៣, យសោធរ, ២០១៨,
- អ៊ីវ ចុង, សាកល្បងសិក្សារឿងរាមកេរ្តិ៍, បណ្ណាគារអង្គរ, ២០១៨
- ឱម ណាគ្រី, សិក្សាអក្សរសាស្ត្រ រឿងរាមកេរ្តិ៍(ពីភាគ១ដល់ភាគ១០), ១៩៦០,
- Saveros Pou, Ramketi(XVI-XVII) រាមកេតិ Paris(6),1997

## ខ. ជាគេហទំព័រ

- http://www.yosothor.org/publications/khmer-renaissance/chapter-two/rerng-ream-ke-ning-ettiphol-knong-phity.html
- https://pressocm.gov.kh/archives/69579(គេហទំព័រទីស្ដីការគណៈរដ្ឋមន្ត្រី)